ខ្ញុំចង់ដឹង



# សត្វ
## នៅកម្ពុជា និងនៅទីដទៃ

SIPAR



នេះជាកូនរមាស។ កាលណា
វាធំឡើង វានឹងមានកម្លាំង
ខ្លាំងណាស់។ វាអាចមាន
ទម្ងន់លើស២តោន ហើយរត់
បាន៤៥គម/ម៉ោ។ រមាសរស់
នៅទ្វីបអាហ្វ្រិក និងទ្វីបអាស៊ី។

SIPAR

អំណោយ
អ្នកឧកញ៉ា ចន្ទី-សារុន

## ខ្ញុំចង់ដឹង



ម.ឯ.ក AIDOC
Code: 172-006
Date:
Donated by:

# សត្វ នៅកម្ពុជា និងនៅទីដទៃ

**អ្នកទទួលខុសត្រូវបោះពុម្ពផ្សាយ :** ហុក សុទ្ធិ - **អ្នកសម្របសម្រួលបោះពុម្ពផ្សាយ :** ហុក សុជាតា
**នាយកសមូហកម្ម :** ស៊ិនហេង ម៉េងឈាង - **អ្នកទទួលខុសត្រូវលើក្រាភិចៈ** ប៉ែន សំបូរណ៍
**អ្នកពិនិត្យអត្ថបទ :** ហែម វ៉ាន់នី, ហុក សាវិទូ និង ហេង ដារី

សៀវភៅនេះ បានទទួលការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ **៣៦៨ អយក.ប្រក.** ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ដើម្បីឱ្យបោះពុម្ពផ្សាយ សម្រាប់ប្រើប្រាស់ជាសៀវភៅអានបន្ថែម នៅតាមសាលារៀនចំណេះទូទៅ។



# មាតិកា


**ថនិកសត្វ** ........ 6

ថនិកសត្វតិណាសី, ថនិកសត្វមំសាសី, ថនិកសត្វទឹក

**បក្សី** ........ 14

បក្សីសត្វរំពា, បក្សីបំលាស់លំនៅ, បក្សីគោក

**ល្មូន** ........ 20

ពួកអណ្តើក, ពួកក្រពើ, ពួកបង្កួយ, ពួកពស់

**កង្កែប** ........ 26

កង្កែប, គីង្គក់, និងសាឡាម៉ង់

**ត្រី** ........ 30

ត្រីទឹកសាប, ត្រីសមុទ្រ, ត្រីចម្លែក

**សត្វឥតឆ្អឹងកង** ........ 38

អាត្រូប៉ូត-សត្វល្អិត, អាត្រូប៉ូតផ្សេងៗទៀត, សត្វឥតឆ្អឹងកងឯទៀតៗ

**យើងជួយការពារសត្វ** ........ 47


# សត្វជា...

**សត្វជាភាវៈរស់មានរូបរាងប្លែកៗ ដែលរស់នៅលើភពផែនដីយើងនេះ។ គេស្គាល់សត្វប្រហែលជា១.៥លានប្រភេទ ហើយនៅមានសត្វជាច្រើនទៀតដែលត្រូវសិក្សាស្វែងយល់ (តាមការប៉ាន់ស្មាន ប្រហែល៣០លានប្រភេទ)។ សត្វទាំងអស់មានលក្ខណៈរួមគ្នាដូចតទៅ:**

- វាកើត លូតលាស់ធំ បន្តពូជ និងស្លាប់ទៅវិញ។
- វាស៊ីរុក្ខជាតិ ឬស៊ីសត្វឯទៀតជាអាហារ។
- វាកំរើក វាផ្លាស់ទីកន្លែង។
- វាដកដង្ហើមស្រូបយកអុកស៊ីសែនពីខ្យល់ ឬពីទឹក។
- វាចេះឈឺចាប់។

ដើម្បីសំគាល់សត្វទាំងនោះ ដែលមានប្រភេទ រូបរាង និងសម្បុរផ្សេងៗ គេចែកពួកវាជា២ក្រុមធំៗគឺ សត្វឆ្អឹងកង និងសត្វឥតឆ្អឹងកង។

# សត្វឆ្អឹងកង



ពួកវាមានគ្រោងឆ្អឹងក្នុង លលាក្បាល ឆ្អឹងខ្នង និងឆ្អឹងជំនីរ។ គ្រោងឆ្អឹងមានភាពរឹងមាំ សម្រាប់ទ្រទ្រង់រូបកាយ ការពារគ្រឿងក្នុងរបស់សត្វ និងចងភ្ជាប់សាច់ដុំទាំងឡាយ។ សត្វឆ្អឹងកងភាគច្រើនមានគ្រោងឆ្អឹងផ្សំដោយឆ្អឹងរឹង ខ្លះទៀតដោយឆ្អឹងខ្ចី។ គេចែកសត្វឆ្អឹងកងទាំងអស់ជា៥ថ្នាក់ :



**ថនិកសត្វ** ប្រហែល ៤ ៥០០ប្រភេទ មាន មនុស្ស សេះ ស្វា បាឡែន...។



**បក្សី** ប្រហែល ៩ ០០០ប្រភេទ មាន សេក ឥន្ទ្រី ក្ងោក ត្រចៀកកាំ...។



**ល្មូន** ប្រហែល ៨ ០០០ប្រភេទ មាន អណ្តើក ក្រពើ បង្កួយ ពស់...។



**កង្កែប** ប្រហែល ៥ ០០០ប្រភេទ មាន កង្កែប គីង្គក់ សាឡាម៉ង់...។



**ត្រី** ប្រហែល ២៤ ៥០០ប្រភេទ មាន ត្រីរៀល ឆ្លាម ត្រីសេះសមុទ្រ...។



# សត្វឥតឆ្អឹងកង

ពួកវាគ្មានឆ្អឹងខ្នង និងគ្មានឆ្អឹងក្នុងទេ។ សត្វខ្លះមានសំបករឹង ដែលជាគ្រោងឆ្អឹងក្រៅសម្រាប់ការពារការប៉ះទង្គិច និងការយាយី ពីសត្វរំពា។ ខ្លះទៀតមានខ្លួនទន់ ហើយគ្មានគ្រោងឆ្អឹងក្រៅទេ។ ពួកវារក្សារូបរាងបាន ដោយសម្ពាធនៃវត្ថុរាវនៅខាងក្នុងខ្លួនវា។ គេចែកពួកវាជា៣០ក្រុម។ ខាងក្រោមនេះជាក្រុមសំខាន់ៗទាំង៦ :



**អាត្រូប៉ូត** ប្រហែល១,១លាន ប្រភេទ មានក្តាម មេអំបៅ ពីងពាង...។



**សិប្បីសត្វ** ប្រហែល១០០ ០០០ ប្រភេទ មានគ្រុំ ខ្យង មឹក...។



**ដង្កូវខ្លួនកង់** ប្រហែល១២ ០០០ ប្រភេទ មានជន្លេន ឈ្លឹង តេញ្ជា...។



**ក្លែ** ប្រហែល៨ ៥០០ ប្រភេទ មានមេឌុយ ផ្កាថ្ម អាណេម៉ូន...។



**អេគីណូឌែម** ប្រហែល៦ ០០០ ប្រភេទ មានតារាអន់ ផ្កាយសមុទ្រ...។



**ស្ប៉ុងស៊ៀ** ប្រហែល១០ ០០០ ប្រភេទ មាន អេប៉ុង...។

# លក្ខណៈខុសៗគ្នា...



សត្វជាច្រើនរស់នៅជាក្រុម ដូចជាសត្វម៉ង់សូ(manchot) ខាងលើនេះ។ ការរស់ជាក្រុមជាហ្វូង ផ្តល់សំណាងឱ្យពួកវាអាចរស់រានមានជីវិតតទល់នឹងសត្រូវ។

ដោយការស្រែកឮ ឆ្កែចចកប្រកាសប្រាប់ហ្វូងឯទៀតថា ពួកវាជាម្ចាស់ដែនដីប្រមាញ់មួយកន្លែងហើយ។

## អាកប្បកិរិយា

ដើម្បីមានជីវិតរស់នៅ សត្វទាំងឡាយត្រូវស៊ី និងជៀសវាងកុំឱ្យគេស៊ីខ្លួនឯង។ ពួកវាក៏ត្រូវបង្កើតកូនចៅផងដែរ ដើម្បីកុំឱ្យផុតពូជ។ តម្រូវការទាំងនេះបង្ខំឱ្យពួកវាមានអាកប្បកិរិយាជាក់លាក់។ អាកប្បកិរិយាខ្លះកើតឡើងដោយការរៀន ខ្លះទៀតកើតឡើងដោយសភាវគតិ។ ឧទាហរណ៍ កូនឆ្កែមិនទាន់ទាំងបើកភ្នែកផង អាចរកក្បាលដោះមេវាដើម្បីបៅ។ នៅចំពោះមុខគ្រោះថ្នាក់ ខ្យងលិបចូលទៅក្នុងសំបក ឯពពួលមូរខ្លួនជាដុំមូល។ អាកប្បកិរិយាសភាវគតិអាចវិវត្ត : កាលណាសត្វធ្វើអំពើមួយដដែលៗ ជាច្រើនលើកច្រើនគ្រា ចំណេះធ្វើរបស់វាក៏ចំរើនប្រសើរឡើង។



## ការទាក់ទងគ្នា

សត្វទាក់ទងឆ្លើយឆ្លងគ្នាដើម្បីរកអាហារ ទាក់ទាញដៃគូ ហៅកូន ឬរត់គេចគ្រោះថ្នាក់... ភាសាតាមរយៈការសំដែងទឹកមុខ ចលនា កិរិយាបថ អាចប្រើការបានពេលនៅជិតៗគ្នា តែពុំអាចប្រើការបានទេនៅក្នុងមហាសមុទ្រ ឬក្នុងព្រៃស្អុក... ក្នុងករណីនេះសត្វត្រូវប្រើសូរ : ឧទាហរណ៍ បាឡែនទាក់ទងគ្នាបានឆ្ងាយម៉ែនទែន ឯសត្វរៃអាចយំឮ





ជាង២គម។ ប្រភេទសត្វនីមួយៗមានសញ្ញាផ្ទាល់ខ្លួន។ សត្វខ្លះដូចជាអំពិលអំពែកប្រើពន្លឺជាសញ្ញា។ សត្វភាគច្រើនក៏បញ្ចេញក្លិនផងដែរ ដើម្បីកំណត់ដែនដី ឬបញ្ជាក់វត្តមានរបស់ខ្លួនប្រាប់ដៃគូ។ សត្វល្អិតឈ្មោលខ្លះរកញីតាមរយៈក្លិន ដែលរសាត់មកតាមខ្យល់។

## ការស៊ីអាហារ

សត្វខ្លះជាមំសាសី ឬមំសាហារសត្វ (ពួកវាស៊ីសាច់ជាអាហារ)។ ខ្លះទៀតជាតិណាសី (ពួកវាស៊ីរុក្ខជាតិជាអាហារ)។ មំសាសីដេញចាប់រំពាដោយប្រើកំលាំង និងល្បឿនលឿនរបស់ពួកវា។ តិណាសីមានធ្មេញ និងក្រពះតម្រូវនឹងការស៊ីរុក្ខជាតិ។ ដោយរុក្ខជាតិមានសារធាតុចិញ្ចឹមតិចជាងសាច់ តិណាសីត្រូវស៊ីច្រើន និងទំពាយ៉ាងយូរ។ សព្វាសីស៊ីសាច់ផង និងស៊ីរុក្ខជាតិផង។ ភាវៈរស់ទាំងអស់ស៊ីគ្នាជាបន្តបន្ទាប់។ គេនិយាយថា ពួកវាបង្កើតជាខ្សែអាហារនៃសារពាង្គកាយ ដែលមានទំនាក់ទំនងនឹងគ្នា។

### សត្វចេះបំភាន់ដែរ ឬទេ?

**ពិតជាចេះ! នៅចំពោះមុខសត្រូវ សត្វមិនបង្ហាញការពិតជានិច្ចនោះទេ។ ឆ្មាច្រើនចំកោងខ្លួន និងឈរជំទើតជើងដើម្បីបន្លំថា ខ្លួនវាធំ។ ត្រីមេអំបៅមានស្នាមខ្មៅមួយធំ រាងដូចភ្នែក សម្រាប់បំភាន់សត្រូវរបស់វាថា ខ្លួនវាធំជាងការពិត។ ឯពស់សម្លាប់កង្កែបម៉្យាងនោះធ្វើពុតជាងាប់ ដើម្បីគេចខ្លួនពីសត្វរំពា។**



**រុក្ខជាតិត្រូវស៊ី ដោយទន្សាយ។**

**ទន្សាយត្រូវស៊ី ដោយឆ្មាព្រៃ។**

**ឆ្មាព្រៃត្រូវស៊ី ដោយឆ្កែចចក។**

**ឆ្កែចចកងាប់ត្រូវស៊ីដោយ រុយ ដង្កូវ ចាក់កើរ និងផ្សិត។**

# ថនិកសត្វជា...

ថ្នាក់ថនិកសត្វមានប្រហែល ៤ ៥០០ប្រភេទ ក្នុងនោះមានមនុស្សផងដែរ។ ពួកថនិកសត្វរស់នៅស្ទើរតែគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ជំរករបស់ពួកវាមាននៅលើដី ក្រោមដី និងក្នុងទឹក។



កូនសេះនេះ ធំល្មមណាស់ នៅជិតមេ។ ពេលឃ្លាន វាតែងទៅបៅដោះមេវា។



## ប្រចៀវ

គឺជាថនិកសត្វតែមួយគត់ ដែលចេះហើរ។ ក្នុងពេលវិវត្តន៍ ម្រាមក៏លូតវែង ឯដៃក៏ក្លាយជាផ្ទាំងស្លាប ដែលមានស្បែកស្តើងទន់ៗ។ ពេលហើរ និងរកផ្លូវក្នុងភាពងងឹត ប្រចៀវបញ្ចេញសូរអ៊ុលត្រា ដែលខ្ទាតមកដល់ត្រចៀកវាវិញ ពេលប៉ះនឹងឧបសគ្គ។

## លក្ខណៈសំខាន់ៗ

**ក្រុម :** សត្វឆ្អឹងកង

**កំដៅខ្លួន :** ឈាមក្តៅ (ថេរកំដៅ) : ៣៧°C ចំពោះមនុស្ស។

**មជ្ឈដ្ឋានរស់នៅ :** លើដី ក្នុងទឹក និងក្នុងខ្យល់។

**ដង្ហើម :** តាមសួត។

**ការបន្តពូជ :** ស្ទើរតែទាំងអស់ ជាសត្វវីវីប៉ា។

**ការការពារខ្លួន :** ស្ទើរតែទាំងអស់ មានរោម។

**អាហារ :** ស៊ីរុក្ខជាតិ ស៊ីសត្វឯទៀត ឬស៊ីសព្វមុខ។




## ការបន្តពូជរបស់ថនិកសត្វ

ថនិកសត្វស្ទើរតែទាំងអស់ជាសត្វវិវីបា។ កូនវាកើតមកជាសត្វតូចៗមានរូបរាងដូចមេបា។ អូវុលរបស់មេរួមជាមួយទឹកកាមរបស់បាអាចបង្កកំណើត ហើយលូតលាស់នៅក្នុងស្បូនរបស់សត្វមេ។ នៅទីនោះ វាប្រែក្លាយបន្តិចម្តងៗទៅជាគភ៌ដោយត្រាំនៅក្នុងទឹកភ្លោះ ហើយទទួលសារធាតុចិញ្ចឹមនិងអុកស៊ីសែនតាមរយៈសុក។ ដំណើរការនេះហៅថា ផើម មានគភ៌ ឬពពោះ។ រយៈពេលផើមប្រែប្រួលទៅតាមប្រភេទសត្វ : ២១ថ្ងៃចំពោះកណ្តុរ, ២ខែចំពោះឆ្កែនិងឆ្មា, ជាង៩ខែចំពោះមនុស្ស, ជាង១ឆ្នាំចំពោះសត្វអូដ្ឋ, និងជិត២ឆ្នាំចំពោះដំរី។ ពេលកើតមកហើយ កូនថនិកសត្វបៅដោះមេវា។ ទឹកដោះមានជាតិស្ករ ខ្លាញ់ អំបិល ប្រូតេអ៊ីន និងវីតាមីនធាតុ ដែលកូនត្រូវការដើម្បីលូតលាស់។

## រោម

ថនិកសត្វមានស្បែកនិងរោម សម្រាប់រក្សាកំដៅខ្លួនឱ្យថេរ។ ស្បែកក្រឡេក្រឡា និងពណ៌ប្លែកៗជួយឱ្យវាបន្លំខ្លួន។ ❶ ស្បែកក្រាស់របស់ដំរី, ❷ រោមវែងក្រាស់របស់សត្វចាមរី (yack), ❸ រោមពណ៌ត្នោត ពពាលស្រអែមរបស់ស៊ីរ៉ាប (សត្វកវែង), ❹ រោមសខ្មៅ ឬត្នោតរបស់សេះបង្កង់, ❺ រោមពណ៌លឿង ឬទង់ដែងពពាលៗរបស់ខ្លារខិន, ❻ រោមពណ៌ប្រផេះលឿងការបស់ឆ្កែចចក។




## ជើង

ជើងរបស់ថនិកសត្វត្រូវទៅនឹងការដើរ និងកន្លែងដែលវារកអាហារ។ ❶ ជើងមូលធំគម្រាំងរបស់ដំរី, ❷ ម្រាមរបស់សត្វស្វា : មេជើងអាចទប់បាននឹងម្រាមឯទៀត, ❸ ក្រចកកន្ទីបបាតរបស់សត្វឆ្មា, ❹ ម្រាមទោលមានក្រចកមួយនៅខាងចុងរបស់ជើងសេះ។



# ថនិកសត្វតិណាសី

**ពួកវាស៊ីស្មៅ ផ្លែឈើ ស្លឹកឈើ និងរុក្ខជាតិជាអាហារ។ ពួកនេះមានធ្មេញរឹងមាំសម្រាប់ខាំទាញ និងទំពាបំបែក។**




## គោ

គោជាថនិកសត្វស្រុក ចតុបាទ និងតិណាសី។ វាជាសត្វទំពាអៀង។ ក្រពះរបស់វាមានថង់៤។ ដំបូងគោទំពាអាហារញ៉ាំៗ គឺពុំល្អិតពេកទេ រួចក៏លេបទៅ។ អាហារនោះចូលទៅក្នុងក្រពះទី១ រួចចូលទៅក្រពះទី២ ដែលនៅទីនោះអាហារនឹងទន់ជ្រាយ។ ពេលសម្រាក គោរើបញ្ចេញអាហារពីក្រពះទី២មកមាត់វិញ។ អាហារនោះក៏បានត្រូវទំពាជាថ្មី (ទំពាអៀង) រួចលេបចូលទៅក្នុងពោះម្តងទៀត។ លើកនេះ អាហារចូលទៅក្នុងក្រពះទី៣ រួចចូលទៅក្រពះទី៤ ហើយក៏ត្រូវកិនរំលាយ។ មេគោខ្មែរឱ្យសាច់ និងកូន។ នៅប្រទេសដទៃ គេចិញ្ចឹមពូជគោឱ្យទឹកដោះ និងពូជគោឱ្យសាច់។

## សត្វខ្ពស់ជាងគេ

**នោះគឺស៊ីរ៉ាប(សត្វកវែង) ដែលរស់នៅក្នុងវាលស្មៅនៃទ្វីបអាព្រិច។ វាមានកវែង និងអាចមានកម្ពស់ដល់៥,៥ម។ កម្ពស់ខ្ពស់ដូចនេះអាចឱ្យវាស៊ីរុក្ខជាតិខ្ពស់ៗ ដែលសត្វឯទៀតមិនអាចស៊ីបាន។**



## ស្វាគោរី (gorille)



ស្វាគោរីស្ថិតនៅក្នុងលំដាប់ព្រីម៉ាត ជាមួយមនុស្សដែរ។ ដោយសារតែខួរក្បាលវារីកចំរើន និងមេជើងវាអាចទប់បាននឹងម្រាមឯទៀត ស្វាមានប្រាជ្ញានិងមានការប៉ិនប្រសប់ក្នុងការធ្វើសកម្មភាពទាំងឡាយជាងសត្វឯទៀតដូចជា វាអាចប្រើដុំថ្មវាយបំបែកសំបកខ្យងខ្ចៅបាន។ ស្វាធំជាងគេបំផុតមានឈ្មោះថា ស្វាគោរី ៖ វាអាចមានកម្ពស់រហូតដល់ ១,៨០ម និងទម្ងន់២០០គក។ វារស់នៅទ្វីបអាព្រិច ជាហ្វូងពី៣ ទៅ ២០ក្បាល។ ពួកវាទាក់ទងគ្នាដោយធ្វើសញ្ញាមុខមាត់ កាយវិការ និងសំរែកប្លែកៗ។ មេបង្កើតកូនម្តងមួយ បន្ទាប់ពីផើម៩ខែ។ កូនតូចរស់នៅជិតមេវារហូតអាយុប្រហែល៤ឆ្នាំ។

## ដំរី

ដោយមានក្បាលធំទើងមើង ស្លឹកត្រចៀកធំៗ ប្រមោយ និងភ្លុកផង ដំរីអាព្រិចជាសត្វគោកធំបំផុត : វាមានប្រវែងខ្លួនដល់៩ម និងទម្ងន់៦ត។ ដំរីអាស៊ីមានមាឌតូចជាង : វាមានប្រវែងខ្លួន៣,៥០ម និងទម្ងន់៥ត។ ដំរីរស់នៅជាហ្វូង ដែលមានដំរីមេចាស់និងមានបទពិសោធជាងគេ ដំរីញីឯទៀត និងកូនៗ។ ដំរីឈ្មោលច្រើនរស់នៅតែឯង និងវិលមករកហ្វូងវិញដើម្បីពាក់មេតែប៉ុណ្ណោះ។ បន្ទាប់ពីអាយុបាន១០ឆ្នាំ ដំរីញីអាចបង្កើតកូនមួយជារៀងរាល់៤ឆ្នាំ។ ដំរីអាចរស់នៅបានដល់អាយុប្រហែល៦០ឆ្នាំ : គឺជាថនិកសត្វអាយុវែងជាងគេបន្ទាប់ពីមនុស្ស។ ដំរីជាសត្វតិណាសី។ វាស៊ីអាហារប្រហែល១៦០គក និងផឹកទឹក២០០ល ក្នុង១ថ្ងៃ។ ដើម្បីស្វែងរកអាហារ ដំរីអាព្រិចតែងតែប្រមូលផ្តុំគ្នាជាហ្វូង ដែលអាចមានដំរីរាប់រយក្បាល។ នៅប្រទេសកម្ពុជា គេឃើញមានដំរីរស់នៅក្នុងព្រៃភោះ ព្រៃឫស្សី និងតំបន់សំបូរស្មៅនៃភូមិភាគឦសាន និរតី និងឧត្តរ។





## សត្វកង់គូរូ (kangourou)

គឺជាថនិកសត្វពិសេស : កូនកើតមកមិនទាន់ពេញរូបរាងទេ។ វាលូនទៅរកថង់ដែលនៅក្រោមពោះមេវា។ វាចូលនៅក្នុងថង់នោះប្រមាណ១៥០ថ្ងៃ ដោយពុំចេញសោះ រហូតដល់ពេញរូបរាង។ សត្វកង់គូរូរស់នៅប្រទេសអូស្ត្រាលី។

# ថនិកសត្វមំសាសី

**សត្វទាំងអស់នេះដេញចាប់ និងសម្លាប់សត្វឯទៀតស៊ីជាអាហារ។ ពួកវាមានថ្គាមរឹងមាំ និងធ្មេញមុតស្រួច ហើយមានវិញ្ញាណពិសេសសម្រាប់រករំពា។**



## ថនិកសត្វលឿនបំផុត

ខ្លាគេប៉ា(guépard)ជាសត្វរត់លឿនជាងគេបំផុតក្នុងចំណោមថនិកសត្វ។ វាអាចរត់ដល់ល្បឿន១០០គម/ម៉ តែអាចបានត្រឹម ៤-៥វិនាទីប៉ុណ្ណោះ។ ខុសពីសត្វឯទៀតក្នុងអំបូរខ្លា ក្រញ៉ាំរបស់វាមិនលើបចូលក្នុងទាំងស្រុងនោះទេ។ ជើងរបស់វាមានលក្ខណៈដូចជើងឆ្កែ។

## ខ្លាធំ

ខ្លាធំជាសត្វធំជាងគេក្នុងអំបូរខ្លា។ វាអាចមានប្រវែងដល់២,៨០ម និងទម្ងន់ដល់៣០០គក។ វារស់នៅក្នុងព្រៃភាគខាងត្បូង និងខាងកើតនៃទ្វីបអាស៊ី និងក្នុងព្រៃតំបន់ស៊ីបេរី។ ដោយសារស្បែកពណ៌ក្រហម លឿង ឬត្នោតខ្ចី និងឆ្នូតបង្ខូចពណ៌ក្រមៅ វាអាចបន្លំខ្លួនក្នុងស្មៅខ្ពស់ៗ និងធ្វើដំណើរមិនឱ្យគេឃើញនៅក្នុងព្រៃ។ ខ្លាជាសត្វរកស៊ីពេលយប់។ វាអាចប្រហារសត្វដែលមានមាឌធំជាងវា ដូចជាក្របី រមាំង និងប្រើសជាដើម។ វាស៊ីសាច់ដល់ទៅ៤០គក ក្នុងមួយលើក។ កូនរបស់វាកើតមកមានភ្នែកបិទ ហើយចាប់បើកភ្នែកនៅ២សប្ដាហ៍ក្រោយមក។ ខ្លាអាចរស់ដល់អាយុ២៥ឆ្នាំ។ នៅកម្ពុជា ខ្លាច្រើនរស់នៅតំបន់ឦសាន ភាគខាងជើង និងភាគនិរតីនៃប្រទេស។





## ខ្លាឃ្មុំសម្បុរត្នោត

សត្វខ្លាឃ្មុំសម្បុរត្នោតអាចមានប្រវែង៣ម និងទម្ងន់១ត ហើយរស់នៅប្រទេសកាណាដា និងរដ្ឋអាឡាស្កា។ វាមានបូកនៅលើខ្នង និងមានក្រញ៉ាំវែងៗ ដែលអាចកាយរកឫសឈើបាន។ វាស៊ីរុក្ខជាតិ ប៉ុន្តែវាក៏ស៊ីត្រី និងសាច់ផងដែរ។ នៅរដូវត្រជាក់ ខ្លាឃ្មុំពួនសំងំនៅក្នុងរូងភ្នំ ឬនៅក្នុងគុម្ពោតឈើប្រហែល៦ខែ។ កូនខ្លាឃ្មុំក៏កើតឡើងនៅក្នុងរដូវនេះដែរ ហើយទទួលកំដៅពីមេរបស់វា។ នៅកម្ពុជា គេឃើញមានខ្លាឃ្មុំធំ (មានរោមពណ៌លឿងរាងជាអក្សរ«V»នៅក្រោមក) និងខ្លាឃ្មុំតូច (មានរោមពណ៌ស លាយលឿងតិចៗរាងជាអក្សរ«U»នៅក្រោមក)។ ខ្លាឃ្មុំរងការគំរាមកំហែង ឈានទៅផុតពូជ ពីព្រោះគេសម្លាប់វាដើម្បីយកមកធ្វើម្ហូប និងថ្នាំកែរោគ។



## ការពួនរងា

នៅក្នុងប្រទេសដែលមានអាកាសធាតុត្រជាក់ ថនិកសត្វមួយចំនួន ដូចជាកណ្តុរខ្មុះ ឬប្រចៀវ សំងំពួនលាក់ខ្លួននៅរដូវរងា។ ពួកវាដេកលក់ស្ងប់ស្ងាត់ដើម្បីសន្សំថាមពលក្នុងខ្លួន។ ខ្លាឃ្មុំជាសត្វពួនរងាពាក់កណ្តាល : វាដេកនៅរដូវត្រជាក់ ប៉ុន្តែវាអាចភ្ញាក់ពីដំណេកយ៉ាងងាយបំផុត។

## ចចកប្រផេះ

ចចកប្រផេះមានធ្មេញមុត និងពូកែស្រូបក្លិនណាស់។ វាជាដូនតារបស់ឆ្កែស្រុក។ វាមានមាឌធំជាងគេក្នុងអំបូរឆ្កែព្រៃ : វាអាចមានប្រវែងដល់១,៥ម និងទម្ងន់៦០គក។ គេប្រទះឃើញវារស់នៅក្នុងព្រៃនៃទ្វីបអឺរ៉ុប អាស៊ី និងអាមេរិចខាងជើង។ វារស់នៅជាហ្វូង ដែលជួនកាលមានរហូតដល់ទៅ២០ក្បាលនៅលើដែនដីដ៏ធំទូលាយ ហើយកំណត់ដែនដីដោយក្លិនទឹកនោម។ ដោយសារហ្វូង វាអាចចាប់សត្វដែលមានទម្ងន់លើសខ្លួនវា១០ដង។ ឆ្កែចចកប្រាប់ពីវត្តមានរបស់ខ្លួនដល់ហ្វូងចចកឯទៀត និងរារាំងចចកទាំងនោះមិនឱ្យមកទន្ទ្រានដែនដីរបស់ខ្លួន ដោយសារសម្រែកលូរបស់វា។ សត្វញីផ្តល់កំណើតដល់កូនពី៤ ទៅ៧ក្បាល ដែលអាចមានជីវិតរស់រហូតដល់អាយុ១៦ឆ្នាំ។



# ថនិកសត្វទឹក

ថនិកសត្វទឹកជាកូនចៅជំនាន់ក្រោយរបស់ថនិកសត្វគោក ដែលបានចុះទៅរស់នៅក្នុងសមុទ្ររាប់លានឆ្នាំមកហើយ។ ពួកវារស់នៅក្នុងទឹក ក៏ប៉ុន្តែត្រូវងើបមកដកដង្ហើមយ៉ាងទៀងទាត់។ សត្វញីបង្កើតកូនម្តងបានមួយក្បាល ហើយបំបៅកូនដោយទឹកដោះ។



## បាឡែន

បាឡែនជាថនិកមច្ឆាគ្មានធ្មេញទេ ។ វាមានបន្ទះជាតិស្នែងរាងដូចក្រាសជំនួសធ្មេញ ។ វាហាមាត់ស្រូបទឹកចូល រួចបញ្ចេញមកក្រៅវិញតាមក្រាសនោះ ឯកូនក្រួស្តាសេ(crustacé)តូចៗហៅថា ក្រឹល(krill) ក៏ជាប់នៅក្នុងមាត់ ហើយត្រូវវាលេបទៅ។ វាអាចស៊ីក្រឹលអស់៤ត ក្នុងមួយថ្ងៃ។ បាឡែនរស់នៅក្នុងសមុទ្រនានាទូទាំងពិភពលោក ។ បាឡែនភាគច្រើនផ្លាស់លំនៅ: ក្នុងរដូវក្តៅពួកវារស់នៅក្នុងសមុទ្រប៉ូល ហើយក្នុងរដូវត្រជាក់ពួកវារស់នៅក្នុងសមុទ្រត្រូពិច ។ បាឡែនប្រភេទខ្លះមុជទៅក្នុងទឹកបានជាងមួយម៉ោង ទើបងើបឡើងមកដកដង្ហើមម្តង ។ បាឡែនត្រូវបានមនុស្សនេសាទហួសកំរិត ដែលធ្វើឱ្យវារងការគំរាមកំហែងផុតពូជ ។

បាឡែនខៀវជាសត្វធំជាងគេបំផុតលើពិភពលោក។ វាអាចមានបណ្តោយប្រវែងដល់ទៅ ៣០ម និងទម្ងន់១៥០ត គឺមានប្រវែងស្មើនឹងដំរី៦ក្បាល។





## ផ្សោត

ផ្សោតជាថនិកសត្វមានធ្មេញ ដែលស៊ីត្រីជាអាហារ។ វារស់នៅជាហ្វូងពី១០ទៅ៥០០ក្បាល ក្នុងមហាសមុទ្រទាំងអស់លើពិភពលោក។ គេមិនទាន់ដឹងច្បាស់ថា ក្រុមទាំងនោះមានការរៀបចំដូចម្ដេចទេ ប៉ុន្តែគេគិតថា ពួកវាគោរពតាមក្បួនច្បាប់សង្គមដ៏ស្មុគស្មាញ។ ពួកវាចេះជួយគ្នាទៅវិញទៅមក។ ប្រសិនបើមានផ្សោតណាមួយត្រូវរបួស ឬឈឺ ផ្សោតមួយផ្សេងទៀតក្នុងហ្វូងហែលរុញវាឱ្យឡើងមកផ្ទៃទឹកខាងលើ ដើម្បីឱ្យវាអាចដកដង្ហើម។ ផ្សោតរកចំណីដោយប្រើសូរខ្ទរ។ វាបញ្ចេញសំឡេងដែលផាលក្នុងទឹក។ លំញ័រនៃសូរសំឡេងរត់ទៅប៉ះនឹងរំពា រួចវាវិភាគសូរខ្ទរ ដើម្បីកំណត់ទីតាំងរបស់រំពានោះ។



## ផ្សោតទន្លេ

ផ្សោតទន្លេរស់នៅក្នុងទឹកនៃតំបន់ដីសណ្ដ នៅតាមសមុទ្រ និងជិតៗឆ្នេរសមុទ្រ។ នៅកម្ពុជា គេឃើញមានផ្សោតប្រភេទនេះនៅក្នុងទន្លេមេគង្គ។ វាមានក្បាលមូល រលោង ភ្នែកតូច ព្រុយខ្នងខ្លីពណ៌លឿងក្រមៅ ដងខ្លួនរលោងគ្មានស្រកា និងគ្មានចំពុះទេ។ វាស៊ីត្រី និងកំពឹស។

## សត្វផ្ទុក (phoque)

សត្វផ្ទុកច្រើនរស់នៅក្នុងសមុទ្រត្រជាក់នៃតំបន់ប៉ូល។ ម្រាមជើងខាងមុខរបស់វាមានក្រចក ចំណែកឯជើងខាងក្រោយមានស្បែកនៅចន្លោះម្រាម។ វាជាអ្នកប្រមាញ់ក្នុងទឹកយ៉ាងស្ទាត់ជំនាញ ដោយសារខ្លួនវាមានរាងស្រលូន និងមានព្រុយមាំៗ។ វាអាចមុជទៅក្នុងទឹករហូតដល់ជម្រៅ៣០០ ឬ៤០០ម ប៉ុន្តែវាត្រូវងើបមកដកដង្ហើមជាទៀងទាត់។ សត្វផ្ទុកមានស្រទាប់ខ្លាញ់ និងស្បែករោមក្រាស់ សម្រាប់ការពារភាពត្រជាក់។ សត្វផ្ទុកប្រភេទខ្លះអាចមានដងខ្លួនប្រវែងដល់៣ម និងទម្ងន់២១៥គក។



# បក្សីជា...

ថ្នាក់បក្សី ឬសត្វស្លាបមានប្រហែល៩ ០០០ប្រភេទ ដែលរស់នៅគ្រប់ទីកន្លែងលើពិភពលោក។ គឺជាក្រុមសត្វតែមួយគត់ដែលមានស្លាប ហើយភាគច្រើនចេះហើរ។




## លក្ខណៈសំខាន់ៗ

**ក្រុម :** សត្វឆ្អឹងកង។

**កំដៅខ្លួន :** ឈាមក្ដៅ (ថេរកំដៅ) ពី៣៧°C ទៅ៤២°C។

**មជ្ឈដ្ឋានរស់នៅ :** លើគោក និងក្នុងអាកាស។

**ដង្ហើម :** តាមសួត។

**ការបន្តពូជ :** ទាំងអស់ជាសត្វអូវីប៉ា (ពងជាស៊ុត)។

**ការការពារខ្លួន :** ទាំងអស់មានស្លាប។

**អាហារ :** ខ្លះស៊ីគ្រាប់ធញ្ញជាតិ ឬផ្លែឈើ ខ្លះទៀតស៊ីសត្វដទៃ។



## ការហើរ

បក្សីជាប់ពូជពីសត្វល្មូន។ ក្នុងពេលវិវត្តន៍ បក្សីបានបង្កើតសម្បទាដែលធ្វើឱ្យវាអាចហើរបាន : គ្រោងឆ្អឹងផ្គុំឡើងដោយឆ្អឹងប្រហោង ស្វិត និងស្រាល ហើយផ្ទាំងស្លាបមានឆ្អឹងមាំសម្រាប់សង្កត់ទៅលើខ្យល់។




## ការបន្តពូជរបស់បក្សី

បក្សីទាំងអស់ជាសត្វអូវីពែ។ វាពងជាស៊ុត។ វាមិនពពោះដូចថនិកសត្វទេ ពីព្រោះខ្លួនវានឹងធ្ងន់ជ្រុលហេតុមិនអាចហើរបាន។ ដោយសារអាហារដែលមាននៅក្នុងស៊ុត និងកំដៅផ្តល់ឱ្យដោយខ្លួនរបស់មេឬបាវា អំប្រ៊ីយ៉ុងលូតលាស់ និងញាស់ជាកូនបក្សី។ ដំណើរការនេះ ហៅថាការក្រាបពង។ បក្សីភាគច្រើនធ្វើសំបុក ដើម្បីរស់នៅ ពង ក្រាបពង និងចិញ្ចឹមកូន។ ពេលញាស់មកភ្លាម កូនបក្សីភាគច្រើនពុំទាន់បើកភ្នែកទេ មានខ្លួនទទេ និងគ្មានអ្វីការពារឡើយ។ មេបាចិញ្ចឹមវារហូតដល់ដុះស្លាប និងអាចហើររកអាហារដោយខ្លួនឯង។




## ជើង

ជើងបក្សីមានរាងតម្រូវទៅតាមមជ្ឈដ្ឋានធម្មជាតិ និងរបៀបដែលវារស់នៅ។ ជើងបក្សីទំមានម្រាមបីមកខាងមុខ និងម្រាមមួយទៅខាងក្រោយ ដើម្បីក្តាប់តោងមែកឈើ ១។ ជើងរបស់បក្សីទឹកមានស្បែកនៅចន្លោះម្រាម សម្រាប់ហែល ២។ ជើងម្រាមពីររបស់សត្វអូទ្រុសតម្រូវនឹងការរត់ ៣។ ជើងបក្សីធ្លាបមានក្រញាំស្រួចៗអាចឱ្យវាចាប់រំពា ៤។

## ចំពុះ

បក្សីគ្មានធ្មេញទេ តែមានចំពុះដែលជាឧបករណ៍មាននាទីច្រើនមុខ ៖ ចឹកចំណីអាហារ សំអាតស្លាប ពាំកំទេចកំទីធ្វើសំបុក និងការពារខ្លួន។ រូបរាងចំពុះប្រែប្រួលទៅតាមការស៊ីអាហារ ៖

១ ចំពុះសំប៉ែតរបស់ទាសម្រាប់ហួរភក់ និងបិចស្មៅ។

២ ចំពុះខ្លី និងខ្លាំងរបស់សេកសម្រាប់ពោះ ឬកកេរគ្រាប់។

៣ ចំពុះវែងស្ទួចរបស់ទីយពាងបក្សីសម្រាប់រុករកសត្វតូចៗក្នុងភក់។

៤ ចំពុះខុបរបស់ធ្លាបសម្រាប់ចឹកចិញ្ច្រាំសាច់។

៥ ចំពុះស្រួចរឹងរបស់សត្វគ្រសេះសម្រាប់ពោះសំបកឈើរកដង្កូវ។

៦ ចំពុះធំស្អឹងរបស់កេងកងសម្រាប់ចឹកផ្លែឈើនៅចន្លោះស្លឹក និងមែកឈើ។



# បក្សីសត្វរំពា



**បក្សីប្រភេទនេះដេញចាប់ និងសម្លាប់សត្វដទៃធ្វើជាអាហារ។ ពួកវាមានភ្នែកមុតមើលឃើញឆ្ងាយ ក្រញ៉ាំខ្លាំងសម្រាប់ច្បាមចាប់រំពា និងចំពុះខុបសម្រាប់ហែកសាច់។**

## ឥន្ទ្រី

ឥន្ទ្រីជាបក្សីឆ្មាបរកស៊ីពេលថ្ងៃ។ វាប្រមាញ់សត្វគ្រប់ប្រភេទដូចជា បក្សី ទន្សាយ ស្វា ឬត្រី នៅតាមតំបន់ដែលវារស់នៅ។ វាច្រើនហើរសំកាំងលើអាកាស ហើយនៅពេលវាឃើញរំពា វាក៏ចោះពួយយ៉ាងលឿនទៅចាប់សម្លាប់រំពានោះ ដោយក្រញ៉ាំរបស់វា។ ឥន្ទ្រីខ្លះដែលស៊ីពស់និងល្មូនជាអាហារ ប្រមាញ់ដោយឈ្លប។ វាទំស៊ឹមនៅលើមែកឈើ ហើយទម្លាក់ខ្លួនទៅចាប់រំពាដែលនៅលើដី។ ផ្ទុយទៅ ឥន្ទ្រីធ្វើសំបុកនៅទីខ្ពស់លើដើមឈើ ឬនៅលើល្បាក់ភ្នំ ហើយវាប្រើសំបុកមួយសម្រាប់ច្រើនឆ្នាំ។ នៅស្រុកខ្មែរយើង ឥន្ទ្រីជាប្រភេទសត្វកំរ។ ជួនកាលគេប្រទះឃើញវានៅភូមិភាគឦសាន ក្នុងរដូវប្រាំង។

### ភ្នែកល្អ

**ប្រសិនបើមនុស្សយើងមានភ្នែកល្អដូចឥន្ទ្រីនោះ យើងនឹងអាចអានចំណងជើងកាសែតបានក្នុងចំងាយ៥០០ម ព្រោះវាអាចមើលឃើញច្បាស់ជាងយើងពី៤ ទៅ៥ដង!**



## មៀម

មៀមជាបក្សីឆ្មាបរាត្រីចរ : វារកស៊ីពេលយប់។ ភ្នែកធំៗរបស់វាអាចចាប់ពន្លឺតិចតួចបាន ហើយត្រចៀកវាពិសេសណាស់។ វាអាចហើរដោយមិនឱ្យឮសំឡេងឡើយ។ វារស់នៅក្នុងសំបុកដែលសត្វឯទៀតបោះបង់ចោល ឬក្នុងប្រហោងដើមឈើ។ មៀមញីពងបានពី២ទៅ៧ស៊ុតក្នុងមួយលើកៗ។ នៅស្រុកខ្មែរ មានមៀមពីរប្រភេទ : មៀមតូចព្រៃ មានខ្នងពណ៌ត្នោតចាស់និងឆ្នូតអុចខ្មៅពេញខ្លួន ឯមៀមខ្លែងមានខ្លួនធំជាង ពណ៌ឈាមជ្រូក និងពោះឆ្នូតធំៗ។



# បក្សីបំលាស់លំនៅ



**បក្សីមួយចំនួនតែងតែផ្លាស់លំនៅទៅតាមរដូវ។ ពួកវាចេញទៅរស់នៅក្នុងតំបន់ផ្សេងទៀតដើម្បីបន្តពូជ ស្វែងរកអាហារ និងគេចពីភាពរាំងស្ងួត ឬភាពត្រជាក់។**



## ត្រចៀកកាំ

ត្រចៀកកាំជាបក្សីតូច មានខ្នងពណ៌ប្រផេះ ឬខ្មៅ ពោះពណ៌ស និងកន្ទុយវែក។ វាអាចធ្វើសំបុកក្នុងប្រហោងដើមឈើ តាមល្បាក់ភ្នំ ឬតាមច្រាំងផ្លូវទឹក។ ត្រចៀកកាំខ្លះផ្លាស់លំនៅ។ ពេលរដូវរងាជិតចូលមកដល់ ពួកវាតែងចាកចោលសំបុកដែលវាបានធ្វើក្នុងតំបន់ត្រជាក់បង្គួរ ហើយហើរទាំងហ្វូងៗ រហូតដល់តំបន់ត្រូពិច ដែលមានអាកាសធាតុក្តៅជាង។ នៅរដូវស្លឹកឈើលាស់ ពួកវាត្រលប់មកសំបុកវិញ។ ឯត្រចៀកកាំនៅស្រុកខ្មែរយើងមិនផ្លាស់លំនៅទេ ហេតុនេះហើយគេប្រទះឃើញពួកវានៅគ្រប់ទីកន្លែង និងគ្រប់រដូវ។

## បក្សីធ្វើដំណើរឆ្ងាយជាងគេ

គឺសត្វស្វែន(sterne) ឬត្រចៀកកាំសមុទ្រ។ ជារៀងរាល់ឆ្នាំ វាផ្លាស់លំនៅរវាងតំបន់អាកទិច និងតំបន់អង់តាកទិច។ ក្នុងមួយឆ្នាំៗ វាហើរចម្ងាយសរុបប្រហែល ៣២ ០០០គម គិតទាំងទៅទាំងមក។



## រនាលពណ៌

ដោយមានក និងជើងវែងៗ រនាលពណ៌អាចមានកម្ពស់ដល់១,៥០ម និងទម្ងន់៤គក។ គេប្រទះឃើញវានៅក្នុងបឹងទឹកប្រៃ តាមសមុទ្រ និងឈូងសមុទ្រ។ ក្រៅពីតំបន់ត្រូពិច រនាលពណ៌ផ្លាស់លំនៅឆ្ងាយៗណាស់ ជួនកាលឆ្ងាយជាង៥០០គម ដោយហើរទាំងពេលយប់ផង។ វារកចំណី (សត្វល្អិត ដង្កូវ និងសារាយតូចល្អិតៗ) ដោយច្រមុជក្បាលទៅក្នុងទឹក ជួនកាលក្នុងរយៈពេលប្រហែល២០វិនាទី។ មេបាទាំងពីរក្រាបពងតែមួយរបស់ពួកវា។ នៅពេលកូនតូចចេះហែលទឹក វាចូលទៅក្នុងក្រុមកូនតូចៗ ដែលមានសត្វពេញវ័យពីរបីក្បាលឃ្លាំមើល។

# បក្សីគោក

**ពួកវាមានផ្ទាំងស្លាបតូច ឬខ្សោយពេកធៀបនឹងទម្ងន់ខ្លួនរបស់វា។ ដោយហេតុនេះ វាហើរបានតិចតួច ឬមិនចេះហើរសោះ ប៉ុន្តែពួកវាពូកែខាងរត់ ឬខាងហែលទឹក។**



**ម៉ង់សូ** (manchot)

សត្វម៉ង់សូរស់នៅជាហ្វូងធំៗក្នុងតំបន់ប៉ូល។ វាមានរោមមិនជ្រាបទឹក និងខ្លាញ់មួយស្រទាប់យ៉ាងក្រាស់ ដែលជួយធ្វើឱ្យខ្លួនវាមានកំដៅ។ វាមិនចេះហើរទេ ប៉ុន្តែវាពូកែហែល និងមុជទឹកយ៉ាងជំនាញ ហើយវាស៊ីត្រីជាអាហារ។ ម៉ង់សូមួយប្រភេទមានអាកប្បកិរិយាពិសេសប្លែកពីគេ។ នៅរដូវត្រជាក់ សត្វមេពងស៊ុតមួយ ហើយទុកឱ្យសត្វបាជាអ្នកក្រាបពង។ បន្ទាប់មកមេក៏ចាកចេញទៅ ហើយត្រលប់មកវិញនៅរដូវស្លឹកឈើលាស់។ សត្វបាផ្ញួនស៊ុតដោយប្រើជើងរបស់វា ដែលមានផ្នត់ស្បែកសម្រាប់ការពារស៊ុត។ សត្វឈ្មោលក្រាបពងនៅផ្តុំជិតៗគ្នា ដើម្បីឱ្យមានកំដៅ។ ក្នុងរយៈពេលនោះ វាពុំស៊ីអ្វីឡើយ។ ពេលសត្វមេត្រលប់មកវិញ វាចិញ្ចឹមកូន ហើយឱ្យសត្វឈ្មោលចេញទៅរកស៊ីអាហារវិញម្តង។



**គីវី** (kiwi)

គីវីរស់នៅក្នុងព្រៃនៃប្រទេស នូវែល សេឡង់។ ផ្ទាំងស្លាបរបស់វាតូចពេកមិនអាចឱ្យវាហើរបានទេ។ ផ្ទាំងស្លាបនេះគ្របដណ្តប់ដោយស្លាប ដែលមានសណ្ឋានដូចរោមវែងៗ។ វាគ្មានកន្ទុយទេ។ បក្សីនេះប្រើចំពុះដ៏វែងរបស់វា (ប្រវែង១៥សម) សម្រាប់រុករើស្លឹកឈើ ដើម្បីរកគ្រាប់ធញ្ញជាតិ ដង្កូវ និងសត្វល្អិត។ វាដេកនៅក្នុងរូងពេលថ្ងៃ និងចេញរកស៊ីពេលយប់។

## ក្ងោក

ក្ងោកបៃតងឈ្មោលជាបក្សីមួយ ក្នុងចំណោមបក្សីស្រស់ស្អាតបំផុតនៅលើពិភពលោក។ វាមានកវែង និងដងខ្លួនគ្របដណ្តប់ទៅដោយស្លាបពណ៌បៃតងភ្លឺ។ ដើម្បីទាក់ទាញសត្វញី ក្ងោកឈ្មោលក្រដាង និងតម្លើងរំភាយកន្ទុយរបស់វា។ ពេលនោះស្លាបវែងៗរបស់វាដែលលំអដោយត្រាមូលៗរាងដូចភ្នែករាប់ពាន់ បង្កើតបានជារង្វង់មានរាងដូចផ្លិត។ ក្ងោកញីមានស្លាបពណ៌ស្រអាប់ និងកន្ទុយខ្លីជាងក្ងោកឈ្មោល ហើយគ្មានត្រាមូលៗទេ។ សត្វញីឱ្យតម្លៃសត្វឈ្មោលទៅតាមកាយវិការរបស់វា។ ក្ងោករស់នៅលើដី ស៊ីគ្រាប់ធញ្ញជាតិ ស្លឹកឈើ និងសត្វល្អិតជាអាហារ។ វាហើរដោយកំរ គឺនៅពេលត្រូវទៅដេកលើដើមឈើ ឬរត់គេចពីគ្រោះថ្នាក់តែប៉ុណ្ណោះ។ នៅកម្ពុជា គេប្រទះឃើញក្ងោកនៅក្នុងព្រៃរបោះ តាមមាត់ទឹក តាមជាយព្រៃ ក្នុងព្រៃឫស្សី និងក្នុងព្រៃស្រោង។



### បក្សីធំបំផុត

**គឺសត្វអូទ្រុស(autruche)។ ខ្លួនវាធំ និងធ្ងន់ជ្រុលរហូតមិនអាចហើរបាន។ ប៉ុន្តែវាអាចរត់ដល់ល្បឿន ៧០គម/ម៉។ វាជាបក្សីតែមួយប្រភេទគត់ ដែលជើងម្ខាងៗមានម្រាមតែពីរ។**



# ល្មូនជា...

អណ្តើក ក្រពើ ថ្លែន ពស់... ជាល្មូន។ ថ្នាក់ល្មូនមានប្រហែល៨ ០០០ប្រភេទ។ ល្មូនស្ទើរតែទាំងអស់រស់នៅក្នុងប្រទេសក្តៅនៃពិភពលោក។




## លក្ខណៈសំខាន់ៗ

**ក្រុម :** សត្វឆ្អឹងកង។

**កំដៅខ្លួន :** ឈាមត្រជាក់ (អាចកំដៅ) ពួកវាត្រូវការកំដៅព្រះអាទិត្យដើម្បីរស់។

**មជ្ឈដ្ឋានរស់នៅ :** លើគោក និងក្នុងទឹក។

**ដង្ហើម :** តាមសួត។

**ការបន្តពូជ :** ភាគច្រើនជាសត្វអូវីប៉ា (បន្តពូជដោយពង)។

**ការការពារខ្លួន :** ទាំងអស់មានស្រកា។

**អាហារ :** ស៊ីសត្វដទៃទៀត។ អណ្តើក និងថ្លែនប្រភេទខ្លះស៊ីរុក្ខជាតិ។



## ដាយណូស័រ

សត្វដាយណូស័រ ដែលបានលេចឡើងកាលពី២២៥លានឆ្នាំមុននេះ និងបានបាត់អស់ទៅវិញកាលពី៦៥លានឆ្នាំមកហើយនោះ ក៏ជាល្មូនដែរ។




## ចេះតែលៀនអណ្តាត!

ពស់ និងបង្គួយភាគច្រើនតែងលៀនអណ្តាតព្រែកជាពីររបស់វា ហើយធ្វើញ័រៗ ដើម្បីស្រូបម៉ូលេគុលខ្យល់ ដែលវាយកមកវិភាគដើម្បីស្គាល់បរិស្ថានជុំវិញ។



## ការបន្តពូជរបស់ល្មូន

ល្មូនភាគច្រើនជាសត្វអូវីពែ។ អណ្តើកពងជាស៊ុតដែលមានសំបករឹង ឬទន់ រួចទេះបង់ស៊ុតទាំងនោះចោល ដោយពុំក្រាបឡើយ។ នៅពេលញាស់ កូនតូចអាចរស់បានដោយខ្លួនឯង។ មានតែអណ្តើកភូមាទេ ដែលរស់នៅក្បែរសំបុកពីរបីថ្ងៃ ដើម្បីដេញពួកសត្វដែលចង់ស៊ីស៊ុតវា។ ក្រពើពងជាស៊ុតនៅក្នុងសំបុកវាក្បែរទឹក។ ក្រពើញីជញ្ជូនកូនតូចៗពីកន្លែងមួយទៅកន្លែងមួយទៀត ដោយពាំនឹងមាត់។ ពស់ពងជាស៊ុតដែលមានសំបកទន់។ ពស់ថ្លាន់មេឡោមរុំព័ទ្ធស៊ុតវា ដើម្បីការពារទប់ទល់នឹងសត្វរំពា ព្រមទាំងផ្តល់កំដៅរហូតដល់ពេលកូនញាស់។ មានល្មូនមួយចំនួនតូចជាសត្វអូវីវីប(ovovivipares)។ សត្វមេរក្សាស៊ុតទុកក្នុងខ្លួនវារហូតដល់ញាស់ រួចបញ្ចេញមកជាកូនមានរូបរាងពេញលេញ។ នេះជាករណីរបស់ពស់ថ្លាន់ប្រភេទបូវ(boas)។

## ជើងស្អិត

ក្រោមជើងជីងចក់ និងតុកកែ មានទ្រនាប់ស្អិត ដែលអាចឱ្យវាដើរនៅលើផ្ទៃបញ្ឈរត្រង់ និងរលីងដូចជាជញ្ជាំងជាដើម ដើម្បីចាប់រំពា ដែលសត្វដទៃទៅមិនដល់។



## ស្បែក ស្រកា និងការសក

ល្មូនទាំងអស់មានស្រការរឹង និងមិនជ្រាបទឹក : ១ អណ្តើក ២ ក្រពើ ៣ កាមេលេអុង ៤ ពស់។ ល្មូនខ្លះដូចជា បង្គួយនិងពស់តែងប្តូរស្បែក នៅពេលវាធំលូតលាស់។ កាលណាស្បែកចាស់របស់វាក្លាយជាតូចចង្អៀត ឬស៊ីករិចរិល វាក៏ប្តូរថ្មី : គេថា វាសក ៥។

# ពួកអណ្ដើក

**អណ្ដើកមានស្នូករឹងមួយធំគ្របខ្លួន។ អណ្ដើកខ្លះរស់នៅលើគោក ខ្លះទៀតរស់នៅក្នុងទឹកសាប ឬក្នុងសមុទ្រ។ អណ្ដើកជាសត្វអាយុវែងណាស់។**



### អណ្ដើកសកល

អណ្ដើកសកលជាអណ្ដើកគោក ដែលរស់នៅក្នុងប្រទេសកម្ពុជា និងនៅតំបន់អាស៊ីអាគ្នេយ៍។ វារស់នៅក្នុងមជ្ឈដ្ឋានសើមសំបូររុក្ខជាតិ មានទឹកមិនហូរ និងមិនសូវជ្រៅ ដូចជាក្នុងវាលស្រែជាដើម។ វាស៊ីខ្យង ខ្ចៅ កំពឹស...។ ស្នូកវាក្រាស់និងមានផាយ-ក្រែងរឹង ខុសពីកន្ធាយដែលមានស្នូកស្តើងនិងផាយក្រែងទន់ៗ។

### អណ្ដើកទឹកសាបធំបំផុត

នោះគឺអណ្ដើកអាលីកាទ័រ (tortue-alligator)។ វាមានទម្ងន់ដល់ទៅ១០០គក ហើយរស់នៅតាមបឹងនិងស្ទឹង ក្នុងភូមិភាគអាគ្នេយ៍នៃសហរដ្ឋអាមេរិក។ ដើម្បីរកអាហារ វាហាមាត់យ៉ាងធំបង្ហាញសាច់ពកពណ៌ផ្កាឈូកក្នុងបំពង់ករបស់វា។ ត្រីទាំងឡាយដែលត្រូវអូសទាញដោយនុយបញ្ឆោតនេះ ក៏ចូលទៅជិតវា ហើយត្រូវវាត្របាក់ស៊ីតែម្ដង។



### ល្មិចព្រុយបី ឬអណ្ដើកសមុទ្រស្នូកស្បែក

ល្មិចព្រុយបីជាអណ្ដើកសមុទ្រធំបំផុត។ វាអាចមានប្រវែងដល់ទៅ២,៤០ម និងទម្ងន់៨៥០គក។ វាធ្វើដំណើរហែលកាត់មហាសមុទ្រ ដើម្បីស្វែងរកមេដុយ(méduse) ឬពពុះទឹក ឬខ្ញែរសមុទ្រ ដែលជាអាហារវាចូលចិត្ត។ វាអាចមុជក្នុងទឹករហូតដល់ជម្រៅ១ ០០០ម ក្នុងរយៈពេលកន្លះម៉ោង។ អណ្ដើកញីតែងតែត្រលប់មកលើឆ្នេរចាស់របស់វាវិញ ដើម្បីពងក្នុងរាត្រីរនោច ដើម្បីកុំឱ្យគេឃើញ។ បន្ទាប់ពីញាស់មកភ្លាម កូនតូចៗរបស់ល្មិចព្រុយបីរត់យ៉ាងលឿនចុះទៅក្នុងសមុទ្រ ដើម្បីគេចពីសត្វរំពា។



# ពួកក្រពើ

**ពួកក្រពើ មានក្រពើ អាលីកាទ័រ(alligator) ក្រពា និងកាវីយ៉ាល់(gavial)។ សត្វទាំងនេះជាសត្វរំពាគួរឱ្យខ្លាច ដែលរស់នៅលើគោកផង និងក្នុងទឹកផង។**



## អាលីកាទ័រទន្លេមីស៊ីស៊ីពី

អាលីកាទ័រទន្លេមីស៊ីស៊ីពី រស់នៅក្នុងភាគអាគ្នេយ៍នៃសហរដ្ឋអាមេរិច។ ពេលលូតលាស់ធំ ស្នាមឆ្នូតពណ៌លឿងក៏រលប់បាត់ ហើយខ្លួនវាទាំងមូលមានសម្បុរខ្មៅ។ វាអាចមានប្រវែងដល់៥ម។ វារកអាហារនៅក្នុងទឹក ឬនៅមាត់ទឹក ដោយចាប់សត្វគ្រប់ប្រភេទស៊ីជាអាហារ។ នៅរដូវក្ដៅ អាលី-កាទ័រចូលចិត្តដេកត្រាំទឹកក្នុងបឹង ឬក្នុងវាលភក់។ នៅរដូវបន្តពូជ សត្វឈ្មោលរោទ៍ដើម្បីទាក់ទាញសត្វញី។ សត្វមេនីមួយៗអាចពងពី២៥ ទៅ៦០ស៊ុតនៅក្នុងសំបុកធំមួយធ្វើពីស្មៅ និងភក់។ នៅពេលវាឮកូនតូចៗរបស់វាស្រែកយំ វាជួយកូនតូចៗទាំងនោះឱ្យចេញពីសំបុក ហើយរស់នៅក្បែរពួកវា៣ឆ្នាំ។



## ក្រពើធំបំផុត

**វាជាក្រពើទឹកប្រៃ ដែលអាចមានប្រវែងដល់ទៅ៧ម និងទម្ងន់១ត។ វារស់នៅក្នុងទឹកសាប និងក្នុងសមុទ្រនៅអាស៊ីអាគ្នេយ៍ និងភាគខាង-ជើងនៃប្រទេសអូស្ត្រាលី។**

## កាវីយ៉ាល់ទន្លេគង្គា

កាវីយ៉ាល់ទន្លេគង្គារស់នៅក្នុងទឹកមិនសូវហូរនៃទន្លេនានានៅឥណ្ឌាភាគខាងជើង និងនេប៉ាល់។ គេងាយនឹងស្គាល់វាដោយសារមាត់វាតូចវែងច្រមុញ ប្រដាប់ដោយធ្មេញតូចៗស្រួចៗ។ វាស៊ីត្រីនិងបក្សីទឹក។ សត្វមេឡើងគោកដើម្បីពងតែប៉ុណ្ណោះ។ មេកាយខ្សាច់ធ្វើសំបុក រួចពងប្រហែល៥០ស៊ុត។ ស៊ុតនីមួយៗមានទម្ងន់ប្រហែល១៥០ក។ វាការកូនតូចៗ។





# ពួកបង្កួយ

**គឺជាល្មូន ដែលមានចំនួនច្រើនជាងគេ។ ពួកវាប្លែកៗពីគ្នា ប៉ុន្តែជាទូទៅ ពួកវាមានជើងបួន និងកន្ទុយមួយវែង។**

## កាមេលេអុង (caméléon)

កាមេលេអុងរស់នៅលើដើមឈើ។ ពណ៌ស្បែករបស់វាដែលប្តូរទៅតាមមជ្ឈដ្ឋានធម្មជាតិជុំវិញ ជួយវាឱ្យបន្លំខ្លួនជាមួយស្លឹកនិងសំបកឈើ។ លើសពីជួយបន្លំខ្លួន ការប្តូរសម្បុរនេះមានប្រយោជន៍ច្រើនទៀត ដូចជា រក្សាសីតុណ្ហភាពខ្លួន ទាក់ទងគ្នា និងទាក់ទាញសត្វញី។ ភ្នែកនីមួយៗអាចកំរើកបានដោយឡែកពីគ្នា ហើយដោយហេតុនេះកាមេលេអុងអាចមើលបានច្រើនទិសក្នុងពេលតែមួយ។ អណ្តាតវែងរបស់វាដែលមានចុងក្រាស់និងស្អិត អាចឱ្យវាចាប់សត្វល្អិតមកបញ្ចូលមាត់បានយ៉ាងងាយ។ វារស់នៅក្នុងទ្វីបអាព្រិច អាស៊ី និងអឺរ៉ុប។

## តុកកែ



តុកកែជាល្មូនរកស៊ីពេលយប់។ វាមានឈ្មោះដូច្នេះ ដោយសារសត្វឈ្មោលយំឮ «តុកកែ! តុកកែ!» ដើម្បីទាក់-ទាញសត្វញី ឬការពារដែនដីរបស់ខ្លួន។ វាអាចមានប្រវែងដល់៣៦សម ហើយមានស្បែកពណ៌ខៀវ ឬប្រផេះ។ ដោយមានស្រទាប់ស្អិតនៅបាតជើង វាអាចវារតាមជញ្ជាំង ឬលើផ្ទៃរលីងៗបាន។ វារស់នៅក្នុងផ្ទះនិងលើដើមឈើនៅតំបន់អាស៊ីអាគ្នេយ៍។ វាស៊ីតុកកែដទៃទៀត និងសត្វល្អិតជាអាហារ។ ពេលទទួលការគំរាមកំហែង វាខាំតបតវិញ។ ឯកន្ទុយវាងាយដាច់ណាស់ដើម្បីទុកបញ្ឆោតសត្រូវ ហើយវាក៏ឆ្លៀតឱកាសរត់គេចខ្លួន។

## បង្កួយធំបំផុត

**គឺជាសត្វអន្សង់កូម៉ូដូ(varan de Komodo) ដែលមានប្រវែង៣ម និងទម្ងន់៧០គក។ វារស់នៅប្រទេសឥណ្ឌូនេស៊ី ហើយប្រហារជ្រូកព្រៃ និងប្រើសតូចៗ។ វាពូកែឡើងដើមឈើ និងហែលទឹកណាស់។ វាច្រើនរស់នៅតាមមាត់ទឹក។**



# ពួកពស់



**ពពួកសត្វពស់គ្មានជើងទេ ហើយផ្លាស់ទីដោយលូន។ ពួកវាសម្លាប់រំពា ដោយចឹកបញ្ចូលពិស ឬដោយរឹតឱ្យថប់ដង្ហើម។ ពស់អាចលេបរំពា ទាំងមូលបាន ដោយសារឆ្អឹងថ្គាមរបស់វាអាចហាបានធំ។**

## ពស់វែករនាម

ពស់វែករនាមរស់នៅក្នុងព្រៃ វាលស្រែ និងទំនាបនៃប្រទេសឥណ្ឌា និងតំបន់អាស៊ីអាគ្នេយ៍។ វាជាប្រភេទពស់ដ៏មានគ្រោះថ្នាក់ ហើយអាចមានប្រវែង៥ម។ នៅពេលវាគិតថាមានគ្រោះថ្នាក់ វាងើបក្បាលអើតឡើងខ្ពស់ផុតពីដីរហូតដល់ ១,៥ម រួចដំឡើងស្បែកកញ្ចឹងកធំ (គេថាពស់ផងកពារ)។ វាសម្លាប់រំពាដោយចឹកបញ្ចូលពិសតាមចង្កូម។ ពស់វែកក្រហមមួយប្រភេទនៅអាព្រិចអាចព្រួសពិសបានចម្ងាយដល់២ម ដែលអាចធ្វើឱ្យសត្វខ្វាក់ភ្នែកមួយរយៈ ឬខ្វាក់ជារៀងរហូត។



**ពិស**

**ពិសរបស់ពស់ខ្លះបញ្ចេញប្រតិកម្មទៅលើប្រព័ន្ធសរសៃប្រសាទ ដោយធ្វើឱ្យសាច់ដុំនៃប្រដាប់ដង្ហើមតាំងលែងដើរ។**

## ពស់ថ្លាន់បៃតង (boa émeraude)

ពស់ថ្លាន់បៃតងមិនមានពិសទេ ដូចពស់ថ្លាន់(python)នៅអាស៊ីអាគ្នេយ៍ និងពស់អាណាកុនដា(anaconda) នៅអាមេរិចខាងត្បូងដែរ។ វាចាប់ និងសម្លាប់រំពាដោយរុំ រួចរឹតខ្លាំងឡើងៗរហូតដល់ស្លាប់ដោយថប់ដង្ហើម។ បន្ទាប់មកវាលេបរំពានោះ ដោយលេបក្បាលទៅមុន។ ពស់ថ្លាន់បៃតងរស់នៅលើដើមឈើនៅអាមេរិចខាងត្បូង។ ពណ៌ស្បែកវា ជួយវាឱ្យបន្លំភ្នែកពួកបក្សីសត្វរំពាបាន។ កន្ទុយផ្ទក់ជាប់និងមែកឈើ ក្បាលទម្លាក់ចុះក្រោម វាសំងំស្ងៀមរង់ចាំចាប់បក្សី ឬថនិកសត្វ ដែលធ្វើដំណើរឆ្លងកាត់ទីនោះ។ វាមានកូនពី៣ ទៅ១៥ ដែលញាស់រៀងរាល់រដូវ ហើយដែលមានសម្បុរដាច់លាប់នៅអាយុមួយឆ្នាំ បន្ទាប់ពីប្តូរពីក្រហម ឬលឿងទៅបៃតង។



# កង្កែបជា...

ថ្នាក់កង្កែបមានសត្វប្រហែល៥ ០០០ប្រភេទ ក្នុងនោះមាន កង្កែប គីង្គក់ សាឡាម៉ង់...។ ពួកវាស្ទើរតែទាំងអស់អាចរស់នៅក្នុងទឹកផង និងលើគោកផង។




## លក្ខណៈសំខាន់ៗ

**ក្រុម :** សត្វឆ្អឹងកង។
**កំដៅខ្លួន :** ឈាមត្រជាក់។ ពួកវាត្រូវការកំដៅព្រះអាទិត្យដើម្បីរស់។
**មជ្ឈដ្ឋានរស់នៅ :** លើគោក និងក្នុងទឹកសាប។
**ដង្ហើម :** កូនតូចតាមស្រកី ពេញវ័យតាមសួតនិងស្បែក។
**ការបន្តពូជ :** សត្វទាំងអស់ជាសត្វអូវីប៉ា (បន្តពូជដោយពង)។
**ការការពារខ្លួន :** ស្បែកទទេ សើម។
**អាហារ :** កូនតូចស៊ីរុក្ខជាតិ ពេញវ័យស៊ីសត្វឯទៀតជាអាហារ។

## សម្បុរស្បែក

សត្វក្នុងថ្នាក់កង្កែបភាគច្រើនមានសម្បុរឆើត។ នេះជាមធ្យោបាយមួយសម្រាប់ការពារខ្លួន និងជាវិធីប្រាប់ដល់សត្វរំពាទាំងឡាយថាស្បែកវាមានជាតិពុល។ សម្បុរក៏ជាមធ្យោបាយសម្រាប់ទាក់ទាញដៃគូ បំភាន់ភ្នែកសត្វរំពា និងកុំឱ្យវាឃើញ ដោយបន្លំខ្លួននឹងរុក្ខជាតិ។




## ការបន្តពូជរបស់ថ្នាក់កង្កែប

សត្វក្នុងថ្នាក់កង្កែបទាំងអស់ជាសត្វអូវីប៉ា។ សត្វភាគច្រើនពាក់ព្វា និងពងនៅក្នុងទឹក។ កង្កែប និងគីង្គក់ធ្វើការបង្កកំណើតក្រៅ ៖ បាស្រោចទឹកកាមពីលើអូវុលដែលមេបញ្ចេញមកក្រៅ ដើម្បីបង្កកំណើត។ អំប្រីយ៉ុងលូតលាស់នៅក្នុងស៊ុតគ្មានសំបក និងការពារដោយជាតិអន្ទិលម្យ៉ាង។ ស៊ុតញាស់ជាកូនក្អុកតូចៗ ដែលមានកន្ទុយ ព្រុយ និងស្រកីក្រៅ។ ក្នុងពេលលូតលាស់ ជើងវាក៏ដុះឡើង ខ្លួនវាក៏មានរាងទ្រវែងជាងមុន ហើយសួតក៏កើតឡើងជំនួសស្រកី ត្រៀមលក្ខណៈឱ្យវាអាចរស់នៅលើគោកបាន។ កន្ទុយរួញខ្លីបន្តិចម្តងៗ។ ការប្រែប្រួលរាងពីកូនក្អុកទៅជាកូនកង្កែបនេះហៅថា បំប្លែង។

## បង្ហើមតាមស្បែក

សត្វក្នុងថ្នាក់កង្កែបមានសួតមែនពិត តែពួកវាស្រូបយកអុកស៊ីសែនមួយភាគធំ ដែលពួកវាត្រូវការតាមស្បែកដ៏ស្តើង និងសំបូរដោយសរសៃឈាម។ ស្បែករបស់វាត្រូវសើមជាអចិន្ត្រៃយ៍។

## អាហារ

សត្វក្នុងថ្នាក់កង្កែបជាមំសាសី។ ពួកវាស៊ីសត្វល្អិត ដង្កូវ និងត្រីតូចៗ ដោយលេបទាំងមូល ពីព្រោះពួកវាមិនអាចទំពាទេ។ ពួកវាចាប់រំពាដែលនៅជិតវា។ ភាគច្រើនរកស៊ីពេលយប់។






## សម្រែក

កង្កែប និងគីង្គក់ល្បោលបំពោងបំពង់ក ហើយស្រែកយំខ្លាំងៗ ដើម្បីទាក់ទាញសត្វញីឱ្យចូលទៅក្នុងកន្លែងមានទឹក ដែលអំណោយផលដល់ការបន្តពូជ។ សត្វប្រភេទនីមួយៗមានសម្រែកផ្ទាល់ខ្លួន។ ដើម្បីស្រែកយំ ពួកវាស្រូបខ្យល់ និងធ្វើឱ្យខ្យល់នោះឆ្លងទៅមកៗរវាងសួតនិងថង់ខ្យល់ (មួយ ឬពីរតាមប្រភេទសត្វ)។ នៅពេលខ្យល់ឆ្លងកាត់ខ្សែសំឡេងនៅក្នុងបំពង់សំឡេង សម្រែកក៏កើតមានឡើង។

# កង្កែប គីង្គក់ និងសាឡាម៉ង់



**កង្កែបមានស្បែករលោង និងសើម ហើយផ្លាស់ទីដោយលោត។ រីឯគីង្គក់មានស្បែកគគ្រើម និងស្ងួត ហើយផ្លាស់ទីយឺតៗ។ ពួកវារស់នៅលើគោកផង និងក្នុងទឹកផង ដូចសាឡាម៉ង់ដែរ។**

## កញ្ជាញ់ចេកហោះ

កញ្ជាញ់ចេកហោះជាកង្កែបមួយប្រភេទ ដែលរស់នៅក្នុងព្រៃនៃតំបន់អាស៊ីអាគ្នេយ៍។ វាមានប្រវែងជាមធ្យម៩សម។ តាមពិតវាមិនហោះទេ តែវាលោតនិងសំកាំងពីដើមឈើមួយទៅដើមឈើមួយ ដោយសារជើងវាមានស្បែកចន្លោះម្រាម ដែលធ្វើដូចជាឆ័ត្រយោង។ វាអាចលោតឆ្ងាយបានចម្ងាយរហូតដល់១០ម។ កង្កែបឈ្មោលតូចជាងកង្កែបញី ហើយមានទ្រនាប់នៅមេជើងសម្រាប់ជួយឲ្យវានិបិតសត្វញីយ៉ាងខ្លាំងក្នុងពេលពាក់គ្នា។ កង្កែបមេពងបានរហូតដល់៨០០ស៊ុតដាក់ក្នុងពពុះការពារ ដែលវាភ្ជាប់នឹងស្លឹកឈើនៅពីលើផ្ទៃទឹក។ ពេលញាស់ កូនក្អុកធ្លាក់ចូលទៅក្នុងទឹក។

## គីង្គក់ឆ្មប



គីង្គក់ឆ្មបមានបណ្ដោយខ្លួនប្រវែងពី៣ ទៅ៥សម។ វាមានរបៀបបន្តពូជប្លែកពីគេ។ គីង្គក់ញីពងស៊ុតមូលៗមួយខ្សែវែង ដែលបន្ទាប់មកវាផ្ទេរទៅឲ្យគីង្គក់បា។ ពេលនោះ គីង្គក់បាស្ពាយខ្សែពងនោះនឹងជើងក្រោយរបស់វា។ ជួនកាលគីង្គក់ឈ្មោលស្ពាយស៊ុត២ខ្សែរបស់មេ២ក្បាលផ្សេងគ្នា។ ពេលស៊ុតជិតញាស់ វាចុះទៅក្នុងទឹករាក់បន្តិច ហើយលែងស៊ុតទាំងនោះចោល។ នៅពេលយប់ គីង្គក់ឆ្មបដើររកស៊ីសត្វឥតឆ្អឹងកងជាអាហារ។ សត្វឈ្មោលទាក់ទាញសត្វញី ដោយបញ្ចេញសម្រែកពិសេសយូរៗម្ដង និងយ៉ាងទៀងទាត់។



## សាឡាម៉ង់ (salamandre)

សាឡាម៉ង់ពពាលមានសម្បុរភ្លើងឆើត ដែលជាសញ្ញាប្រាប់ដល់សត្វវីពាទាំងឡាយថា ខ្លួនវាមានពិស ៖ វាបញ្ចេញសារធាតុពុលម្យ៉ាង ដែលមានរសជាតិអាក្រក់ណាស់។ វារស់នៅក្នុងព្រៃដែលមានសីតុណ្ហភាពបង្គួរនៃទ្វីបអឺរ៉ុប និងអាព្រិចខាងជើង ហើយនៅរដូវត្រជាក់ វាចូលក្នុងដី។ វាច្រើនចេញរកស៊ីនៅពេលយប់។ វាស៊ីដង្កូវ ខ្យង និងសត្វល្អិត។ ស៊ុតលូតលាស់នៅក្នុងខ្លួនសត្វមេ ខុសប្លែកពីកង្កែបនិងគីង្គក់។ សត្វមេពងក្នុងត្រពាំង ឬអូរ។ កូនញាស់លូតលាស់រហូតដល់ដំណាក់បំរែរូប។ ស្រកីរបស់វាក៏រួញបាត់ ហើយសួតក៏ដុះជំនួសវិញ ប៉ុន្តែកន្ទុយនៅមានដដែល។ បន្ទាប់មក វាឡើងមករស់នៅលើគោក។ សាឡាម៉ង់ប្រភេទខ្លះរស់នៅក្នុងទឹកជារៀងរហូត។

### កង្កែបធំជាងគេ

គឺកង្កែបគោលីយ៉ាត(goliath)។ កង្កែបឈ្មោលអាចមានប្រវែង ៤០សម។ វារស់នៅទ្វីបអាព្រិចខាងលិច តាមបណ្ដោយអូរក្នុងព្រៃស្ងួត ហើយស៊ីកង្កែប ល្អូនតូចៗ និងចនិកសត្វជាអាហារ។



# ត្រីជា...

ថ្នាក់ត្រីមានប្រហែល២៤ ៥០០ប្រភេទ ដែលរស់នៅក្នុងទឹកសាប និងទឹកប្រៃ។ ត្រីផ្លាស់ទីដោយហែលនឹងព្រុយ ហើយដកដង្ហើមតាមស្រកី។




## លក្ខណៈសំខាន់ៗ

**ក្រុម** : សត្វឆ្អឹងកង។

**កំដៅខ្លួន** : ឈាមត្រជាក់ ប្រែប្រួលទៅតាមកំដៅទឹក។

**មជ្ឈដ្ឋានរស់នៅ** : ក្នុងទឹកសាប ឬទឹកប្រៃ។

**ដង្ហើម** : តាមស្រកី។

**ការបន្តពូជ** : ភាគច្រើនជាសត្វអូវីប (បន្តពូជដោយពង)។

**ការការពារខ្លួន** : ស្រកាវែង បន្លះឆ្អឹងធ្មុង ឬស្បែកទន់។

**អាហារ** : ស៊ីរុក្ខជាតិទឹក ឬសត្វឯទៀត។

## ប្លោក

ត្រីឆ្អឹងមានថង់ខ្យល់មួយនៅក្នុងពោះ ដែលគេហៅថាប្លោក។ វាអាចបណ្តែតខ្លួន មុជចុះ ឬងើបឡើងលើបាន ដោយតម្រូវមាឌនិងសម្ពាធខ្យល់ ដែលមាននៅក្នុងប្លោកនោះ។




## ការបន្តពូជរបស់ត្រី

ត្រីស្ទើរតែទាំងអស់ជាសត្វអូវីប៉ា។ ជាទូទៅ ត្រីមេទម្លាក់ពងរាប់ពាន់ តូចៗ ថ្លាៗ និងគ្មានសំបក។ ត្រីឈ្មោលស្រោចទឹកកាមពីលើពងទាំងនោះ។ តាមប្រភេទត្រី ពងទាំងនោះអាចអណ្តែតលើផ្ទៃទឹក ធ្លាក់ទៅបាតបឹង ឬទៅជាប់នឹងស្លឹករុក្ខជាតិ។ ក្នុងចំណោមកូនញាស់តូចៗដែលកើតចេញពីពង ភាគច្រើនត្រូវសត្វដទៃស៊ីមុននឹងធំពេញវ័យ។ ត្រីជាច្រើនគ្មានទំនាក់ទំនងជាមួយនឹងកូនរបស់វាទេ ប៉ុន្តែត្រីប្រភេទខ្លះការពារកូនតូចៗរបស់ខ្លួន។ ត្រីខ្លះធ្វើសំបុក ហើយវាសំអាតដើម្បីជៀសវាងការឆ្លងរោគ ឬវាបក់ឱ្យមានខ្យល់ចេញចូលដើម្បីផ្តល់អុកស៊ីសែន។ ត្រីទីឡាព្យ៉ា បើកមាត់យ៉ាងធំដើម្បីឱ្យកូនចូលជ្រកនៅពេលមានអាសន្ន។ ងត្រីរ៉ស់ និងត្រីឆ្តោបណ្តើរកូនទាំងហ្វូងៗ មុននឹងលែងពួកវាចោល។

## មាត់ និងធ្មេញ

មាត់ត្រីមានសណ្ឋានត្រូវនឹងរបៀបរកអាហាររបស់វា។ ត្រីបារ៉ាគូដា(barracuda) មានមាត់វែងប្រកបដោយធ្មេញស្រួចៗសម្រាប់ចាប់រំពា។ ត្រីបូដ្រ័រ(baudroie) មានមាត់ធំសម្រាប់លេបត្រីឯទៀតទាំងមូល។ ត្រីហារ៉េង(hareng) ត្រងយកប្លង់តុង ដោយប្រើសរីរាង្គជាប់នឹងស្រកីរបស់វា។ ត្រីឆ្លាមខ្លះមានធ្មេញប្រាំបីជួរនៅលើថ្គាមនីមួយៗ។ ធ្មេញវាធាក់ជាញឹកញយ នៅពេលវាខាំស៊ីរំពា ប៉ុន្តែធ្មេញទាំងនោះដុះវិញយ៉ាងឆាប់រហ័ស។ វាអាចមានរហូតដល់៣០ ០០០ធ្មេញ ក្នុងមួយជីវិតរបស់វា។






## ដកដង្ហើមក្នុងទឹក

ត្រីដកដង្ហើមដោយសារស្រកី ដែលជាបន្ទះឆ្អឹងខ្ចីទ្រៀកៗ សំបូរដោយសរសៃឈាម ស្ថិតនៅចំហៀងសងខាងក្បាល។ ពេលត្រីហាមាត់ ទឹកដែលមានអុកស៊ីសែនក៏ចូលទៅក្នុងមាត់ពេញ។ ពេលត្រីបិទមាត់ ទឹកច្រាលទៅស្រោចលើស្រកី រួចចេញមកក្រៅវិញ។ អុកស៊ីសែនត្រូវស្រកីស្រូបយក ហើយជ្រាបចូលទៅក្នុងឈាម ដែលមាននាទីដឹកជញ្ជូនទៅចែកចាយដល់សរីរាង្គទាំងឡាយ។

# ត្រីទឹកសាប

ត្រីទឹកសាបមានប្រហែល១០ ០០០ប្រភេទ ដែលរស់នៅក្នុងទន្លេ ស្ទឹង និងបឹង។ ត្រីខ្លះផ្លាស់លំនៅ ត្រីខ្លះទៀតរស់នៅក្នុងមជ្ឈដ្ឋាន ដែលវាបានកើតអស់មួយជីវិត។



### វាមានឈ្មោះបី

ប្រសិនបើវាមានសំណាងរស់រហូតដល់ចាស់ ត្រីនេះនឹងមានឈ្មោះបី :

- នៅតូចគេហៅ ត្រីដៀប។
- ពេលធំគេហៅ ត្រីឆ្តោ។
- ពេលធំមែនទែន គេហៅ ត្រីភហ្វ ដែលអាចមានប្រវែងរហូតដល់១ម។



### ត្រីអេស្ទូស្យុង (esturgeon)

ត្រីអេស្ទូស្យុងហែលឡើងតាមទន្លេ ដើម្បីទៅបន្តពូជ។ កូនវារស់នៅក្នុងទន្លេនោះជាច្រើនឆ្នាំ មុននឹងហែលចុះទៅរស់នៅក្នុងសមុទ្រ នៅពេលពេញវ័យ។ វារស់នៅទ្វីបអាមេរិច ទ្វីបអឺរ៉ុប និងទ្វីបអាស៊ី។ វាជាត្រីរងគ្រោះថ្នាក់ និងក្លាយទៅជាប្រភេទត្រីកំរ ដោយសារគេចូលចិត្តនេសាទដើម្បីយកពង។ ដងខ្លួនវាវែង រៀវស្រួច គ្មានស្រកា គ្របដណ្ដប់ដោយឆ្អឹងពកក្រាស់ៗ សម្រាប់ការពារ។ មាត់វែងហើយស្រួចអាចឱ្យវារុករើភក់ ដើម្បីរកដង្កូវ កូនញាស់ ខ្យងខ្ចៅ គ្រូស្តាសេ និងត្រីតូចៗ។ មាត់វាគ្មានធ្មេញទេ។ វាជាសត្វនៅមានជីវិតសល់ពីកាលបុរេប្រវត្តិ ហើយសព្វថ្ងៃក៏នៅមានរូបរាងប្រហែលនឹងរូបរាងរបស់វាក្នុងសម័យនោះដែរ។



## ត្រីរៀល

ត្រីរៀលជាត្រីតូច (ប្រវែងខ្លួនពី១៥ ទៅ២០សម) មានស្រកាតូចៗពណ៌ប្រាក់ភ្លឺផ្លេក។ គេឃើញវារស់នៅក្នុងបឹង និងទន្លេនៃប្រទេសកម្ពុជា។ វាជាត្រីស្លូត ហើយស៊ីសារាយ និងសារពាង្គកាយតូចៗដែលអណ្តែតក្នុងទឹក។ វាជាមច្ឆាសាយកូនណាស់។ នៅរដូវទឹកស្រក ត្រីរៀលធ្វើដំណើរជាហ្វូងធំៗ ចុះតាមបណ្តោយខ្សែទឹក ពីបឹងទន្លេសាបឆ្ពោះទៅទន្លេមេគង្គ។ ជារៀងរាល់ឆ្នាំ នៅក្នុងទន្លេសាបគេនេសាទត្រីរៀលបានច្រើន ចាប់ពីខែតុលា ដល់ខែកុម្ភៈ។



## ត្រីពូជថ្មីក្នុងបឹងទន្លេសាប

នៅឆ្នាំ២០០៥ អ្នកស្រាវជ្រាវមួយក្រុមបានប្រទះឃើញត្រីទឹកសាបមួយប្រភេទថ្មីនៅប្រទេសកម្ពុជា។ ត្រីប្រភេទនេះធំជាងត្រីរៀលបន្តិចហើយមិនពូកែហែលទឹកទេ។ ត្រីនេះទំនងជាចេញពីទន្លេមេគង្គ ហើយទៅរស់នៅក្នុងភក់បាតបឹងទន្លេសាបរាប់ពាន់ឆ្នាំមកហើយ។

## ត្រីពីរ៉ាញ៉ាក្រហម (piranha rouge)

ត្រីពីរ៉ាញ៉ាក្រហមធំបំផុតមានប្រវែងប្រហែល៣០សម និងទម្ងន់១គក។ វាមានខ្នងពណ៌ប្រាក់ និងពោះពណ៌ក្រហមឆើត។ វារស់នៅជាហ្វូងក្នុងបឹង និងទន្លេនានានៅអាមេរិចខាងត្បូង។ វាមានធ្មេញតូចៗ ហើយស្រួចៗ រាងត្រីកោណ និងមានថ្គាមរឹងមាំខ្លាំងណាស់។ ពេលព្រឹក និងពេលល្ងាច វាចេញរកស៊ីត្រី សត្វទឹកឥតឆ្អឹងកង និងជាពិសេសសត្វល្អិត ប៉ុន្តែវាក៏ស៊ីគ្រាប់ធញ្ញជាតិ និងផ្លែឈើផងដែរ។ ប្រសិនបើមានឱកាស ត្រីដ៏សាហាវនេះអាចប្រហាររំពាដែលមានមាឌធំជាងខ្លួនច្រើនដង។ ហ្វូងត្រីពីរ៉ាញ៉ាអាចចិកស៊ីគោមួយក្បាលអស់តែក្នុង២-៣នាទីប៉ុណ្ណោះ។



# ត្រីសមុទ្រ

ក្នុងចំណោមត្រីប្រហែល១៤ ០០០ប្រភេទ ដែលរស់នៅក្នុងសមុទ្រនិងមហាសមុទ្រ មានត្រីខ្លះរស់នៅក្បែរផ្ទៃទឹក ត្រីខ្លះទៀតរស់នៅបាតសមុទ្រក្នុងជំរៅជាង១១ ០០០ម។



### ត្រីលឿនបំផុត

គឺត្រីទូកក្ដោង(voilier) នៅក្នុងមហាសមុទ្រអាត្លង់ទិច។ វាអាចហែលដល់ល្បឿន១០០គម/ម៉។ វាមានព្រុយខ្នងធំ រាងដូចក្ដោងទូក និងអាចមានប្រវែងដល់៣ម។ វាក៏រស់នៅក្នុងសមុទ្រក្ដៅ និងត្រជាក់បង្គួរផងដែរ។

### ត្រីឆ្លាមស៊ីប្លង់តុង (requin pèlerin)

ត្រីឆ្លាមប្រភេទនេះមានគ្រោងឆ្អឹងជាឆ្អឹងខ្ចីម៉ាំៗ និងអាចរលាស់បាន។ វាអាចមានប្រវែងរហូតដល់១៥ម និងទម្ងន់ជាង៦ត។ វាមិនកាចសាហាវទេ។ វាស៊ីតែប្លង់តុងដែលវាប្រមូលយកពីទឹកសមុទ្រ ដោយត្រងតាមស្រកី។ វារស់នៅក្នុងទឹកស្រទាប់លើ ក្បែរៗឆ្នេរនៃសមុទ្រទូទាំងពិភពលោក។ មានត្រីឆ្លាមប្រភេទផ្សេងជាច្រើនទៀតរស់នៅកណ្ដាលសមុទ្រ ហើយពួកវាក៏រសឹងហែលចូលមកជិតឆ្នេរណាស់។ ត្រីឆ្លាមភាគច្រើន ជាអ្នកប្រមាញ់គួរឱ្យខ្លាច។ ពួកវាមានច្រមុះពូកែស្រួចក្លិនណាស់ ឆ្អឹងថ្គាមម៉ាំៗ និងធ្មេញមុតស្រួច។ វាស៊ីសត្វគ្រប់ប្រភេទ ស៊ីរហូតដល់ត្រីឆ្លាមតូចៗទៀតផង។





## ត្រីទេព (poisson-ange)

ត្រីប្រភេទនេះរស់នៅឯកោក្នុងទឹកមិនសូវជ្រៅ (ជំរៅពី២ ទៅ២០ម) នៃមហាសមុទ្រឥណ្ឌា និងប៉ាស៊ីភិច។ គេក៏អាចប្រទះឃើញវានៅប្រទេសកម្ពុជាផងដែរ។ វាស៊ីសារាយ សត្វឥតឆ្អឹងកងតូចៗ និងអេប៉ុងដែលមានច្រើននៅលើថ្មផ្កាថ្មប៉ប្រះទឹក។ ត្រីតូចនិងត្រីពេញវ័យ ខុសគ្នាឆ្ងាយណាស់ : ត្រីតូចមានសម្បុរខ្មៅ ឬខៀវ និងរំលេចដោយរង្វង់ពណ៌ស ឯត្រីពេញវ័យមានឆ្នូតពណ៌លឿង និងស្វាយស្រស់ឆើតឆាយ។

## ត្រីអណ្តាតឆ្កែសមុទ្រ (turbot tropical)

ត្រីអណ្តាតឆ្កែសមុទ្រជាត្រីសំប៉ែត ដែលរស់នៅក្នុងសមុទ្រក្រហម ក្នុងមហាសមុទ្រឥណ្ឌា និងប៉ាស៊ីភិច។ ពេលចំលូតលាស់ កូនត្រីអណ្តាតឆ្កែប្រែរូប : ខ្លួនរបស់វាឡើងសំប៉ែត ហើយភ្នែកម្ខាងរំកិលទៅជិតភ្នែកម្ខាងទៀត ជួនកាលរំកិលទៅចំហៀងខាងឆ្វេង ជួនកាលទៅចំហៀងខាងស្តាំ។ មាត់របស់វាវៀច និងមានធ្មេញតែនៅខាងចំហៀងគ្មានភ្នែក។ ដោយហេតុនេះ វាស៊ាំទៅនឹងជីវិតនៅបាតសមុទ្រ តែជួនកាលវាក៏ហែលឡើងមកជំរៅមធ្យមផងដែរ ដើម្បីរកចំណី។





## ត្រីស៊ូម៉ុងអាត្លង់ទិច

ត្រីធំនេះអាចមានប្រវែងដល់ ១.៥០ម។ សាច់វាមានរសជាតិឆ្ងាញ់ពិសា។ បន្ទាប់ពីញាស់ និងរស់ ៤ឆ្នាំនៅក្នុងទឹកសាប ត្រីស៊ូម៉ុង ផ្លាស់ទីដោយហែលចុះមករស់នៅក្នុងមហាសមុទ្រវិញ។ លុះដល់វ័យបង្កកំណើត វាហែលឡើងតាមស្ទឹង ដែលវាបានកើត ដើម្បីទៅពងកូន។ ត្រីមេទម្លាក់ពង។ ត្រីឈ្មោលបញ្ចេញទឹកកាមស្រោចពីលើ។ បន្ទាប់មក ដោយអស់កម្លាំងពេក ត្រីពេញវ័យទាំងនោះ ក៏បណ្តែតខ្លួនឱ្យរសាត់តាមទឹក ដើម្បីត្រលប់មកសមុទ្រវិញ។

# ត្រីចម្លែក

ត្រីខ្លះមានរូបរាង របៀបរស់នៅ ឬមធ្យោបាយការពារខ្លួនខុសប្លែកពីត្រីធម្មតា។





**ឡាំព្រ័រ (lamproie)**

ត្រីឡាំព្រ័រមានគ្រោងឆ្អឹង ប៉ុន្តែគ្មានឆ្អឹងថ្គាមទេ។ មាត់របស់វាមានធ្មេញមុតៗដុះជាជួរ។



**ត្រីផ្សូផុង (diodon)**

នៅចំពោះមុខគ្រោះថ្នាក់ ត្រីកំពតម្យ៉ាងឈ្មោះត្រីផ្សូផុង ស្រូបទឹក បំប៉ោងខ្លួនឡើងធំមូលដូចបាល់ ហើយបំប៉ះបន្លាឡើងផង។ ឆ្អឹងថ្គាមមាំ ដែលមានធ្មេញរឹងមាំ អាចឱ្យវាខាំបំបែកសំបកខ្យង ខ្ទៅ ឬក្តាមបាន។ វារស់នៅក្នុងជួរផ្កាថ្មប៉ប្រះទឹកនៃតំបន់ក្តៅក្នុងពិភពលោកទាំងមូល។ ឯត្រីកំពតដែលរស់នៅក្នុងបឹង ឬទន្លេនៃប្រទេសកម្ពុជា មានអាកប្បកិរិយាដូចគ្នានឹងត្រីផ្សូផុងដែរ។ នៅមុខសត្រូវ វាបំប៉ោងខ្លួនដើម្បីបន្លាចដោយបន្លំថាខ្លួនវាធំ ប៉ុន្តែវាគ្មានបន្លាទេ។ សាច់របស់វាមានរសជាតិឆ្ងាញ់ពិសា ប៉ុន្តែផ្នែកខ្លះនៃខ្លួនវាមានជាតិពុល។



## អន្ទង់មុយរ៉ែន (murène)

អន្ទង់មុយរ៉ែនទន់ភ្លន់ណាស់ ដោយសារឆ្អឹងខ្នងរបស់វាមានឆ្អឹងកងជាង ១០០កង់។ វាស្រដៀងនឹងសត្វពស់ដែរ។ វារស់នៅតាមឆ្នេរសមុទ្រត្រូពិច ដូចនៅប្រទេសកម្ពុជាជាដើម ហើយពួនលាក់ខ្លួននៅក្នុងរូងនៃថ្នាំងថ្ម ដោយសំងំរង់ចាំឱ្យរំពាចូលមកជិត ដើម្បីនឹងត្របាក់ស៊ី។ មាត់របស់វាមានធ្មេញស្រួចៗ។



## ត្រីហោះ

ពេលទទួលការគំរាមកំហែង វាបក់កន្ទុយយ៉ាងរហ័ស រួចត្រដាងព្រុយទ្រូងដែលមានផ្ទៃធំរឹង រាងដូចស្លាប ហើយស្ទុះលោតផុតពីទឹក។ វាអាចសំកាំងលើផ្ទៃសមុទ្រក្នុងល្បឿន ៦៥គម/ម៉ ក្នុងរយៈពេល១២វិនាទី។ វារស់នៅក្នុងគ្រប់សមុទ្រត្រូពិចទាំងអស់ ហើយមានប្រវែងរហូតដល់ ១៨សម។ ប្រភេទខ្លះរស់នៅក្នុងមហាសមុទ្រអាត្លង់ទិចខាងជើងផងដែរ ហើយមានប្រវែងរហូតដល់៤០សម។

## ត្រីសេះសមុទ្រ

ដោយមានក្បាលរាងដូចក្បាលសេះ និងខ្លួនគ្របដណ្តប់ដោយបន្ទះឆ្អឹង ត្រីសេះសមុទ្រជាត្រីសមុទ្រចម្លែកមួយ។ វាហែលឈរដោយប្រើព្រុយខ្នងរបស់វា ហើយអាចប្រើកន្ទុយផ្ទក់នឹងសារាយដើម្បីទប់ខ្លួន។ វាស៊ីប្លង់តុងជាអាហារ។ ការបន្តពូជរបស់វាក៏ពិសេសណាស់ដែរ។ ត្រីសេះសមុទ្រមេពងជាស៊ុតដាក់ក្នុងថង់ពោះរបស់ត្រីឈ្មោលជាបា ដែលមានភារកិច្ចថែរក្សា និងភ្ញាស់។ ពី២ទៅ៥សប្តាហ៍ក្រោយមក ស៊ុតក៏ញាស់ រួចត្រីឈ្មោលបញ្ចេញកូនតូចៗពីក្នុងថង់។



# សត្វឥតឆ្អឹងកងជា...

សត្វឥតឆ្អឹងកងជាសត្វគ្មានឆ្អឹងខ្នង។ ថ្វីបើពួកវាមានចំនួនច្រើនលើសលុបក្នុងចំណោមពពួកសត្វទាំងអស់ (៩៧%) ក៏គេមិនសូវស្គាល់ពួកវា ដូចពពួកសត្វឆ្អឹងកងដែរ។




## តួនាទីរបស់សត្វល្អិត

បើគ្មានសត្វល្អិតទេ រុក្ខជាតិនានានឹងវិនាសផុតពូជមិនខាន ពីព្រោះគឺពួកវានេះហើយ ដែលជញ្ជូនលំអងផ្កាពីរុក្ខជាតិមួយទៅរុក្ខជាតិមួយទៀត ធ្វើឱ្យរុក្ខជាតិទាំងនោះអាចបន្តពូជបាន។ សត្វល្អិតក៏មានប្រយោជន៍ផ្សេងទៀតដែរ ដូចជាជួយសំអាតធម្មជាតិ និងកែច្នៃអ្វីដែលងាប់ទៅហើយ។

## លក្ខណៈសំខាន់ៗ

**ក្រុម :** សត្វឥតឆ្អឹងកង។

**កំដៅខ្លួន :** ឈាមត្រជាក់។ ពួកវាត្រូវការកំដៅថ្ងៃដើម្បីរស់។

**មជ្ឈដ្ឋានរស់នៅ :** លើគោក ក្នុងទឹក ក្នុងដី។

**ដង្ហើម :** ប្រែប្រួលទៅតាមសរីរាង្គ។

**ការបន្តពូជ :** ដោយភេទ និងដោយឥតភេទ។

**ការការពារខ្លួន :** មានស្នូក គ្រោងឆ្អឹងក្នុង ឬក្រៅ។

**អាហារ :** ស៊ីរុក្ខជាតិ ឬសត្វដទៃទៀតជាអាហារ។




## ការបន្តពូជរបស់សត្វឥតឆ្អឹងកង

សត្វឥតឆ្អឹងកងបង្កើតកូនចៅតាមការបន្តពូជដោយភេទ ឬការបន្តពូជដោយឥតភេទ។ ក្នុងការបន្តពូជដោយភេទ សត្វ២ក្បាលប្រភេទដូចគ្នា តែភេទខុសគ្នា (មួយញី មួយឈ្មោល) ពាក់គ្នា។ បន្ទាប់មក សត្វមេឱ្យកំណើតជាកូនតូចៗ។ សត្វឥតឆ្អឹងកងសមុទ្រខ្លះបង្កកំណើតក្រៅ ហើយបន្តពូជដោយគ្មានការរួមភេទឡើយ ៖ សត្វមេបញ្ចេញអូវុល (កោសិកាបន្តពូជញី) សត្វបាបញ្ចេញស្ពែម៉ាតូស៊ូអ៊ីត (កោសិកាបន្តពូជឈ្មោល) ចោលទៅក្នុងទឹក។ អូវុល និងស្ពែម៉ាតូស៊ូអ៊ីតរលាយចូលគ្នា បង្កើតបានជាស៊ុត រួចញាស់ជាកូន ដែលមានលក្ខណៈខុសគ្នាបន្តិចបន្តួចពីមេបារបស់វា។ ឯក្នុងការបន្តពូជដោយឥតភេទវិញ សត្វមួយក្បាលដើរតួជាមេផង និងជាបាផង ៖ ឧទាហរណ៍ អាណេម៉ូនសមុទ្រផ្តាច់ខ្លួនជាពីរ ដើម្បីបង្កើតសត្វថ្មីមួយ ដែលមានលក្ខណៈដូចមេបេះបិទ។

## ពុក

គឺជាសរីរាង្គវិញ្ញាណដ៏សំខាន់ ដែលនៅជាប់នឹងក្បាលរបស់សត្វល្អិត។ ពុកមានចំនួនគូចល័ត ហើយអាចប្រើសម្រាប់ស្ទាប ទទួលសំឡេង ធុំក្លិន និងដឹងរសជាតិ។ មាឌ និងរូបរាងរបស់ពុកប្រែប្រួលទៅតាមប្រភេទសត្វ។



## ភ្នែក

ភ្នែកសត្វល្អិតខ្លះមានកែវភ្នែកតូចៗរាប់ពាន់ ដែលជាប់ជាប់គ្នីណាស់។ ភ្នែករបស់វាអាចមើលឃើញទូលាយ ហើយស៊ាំទៅនឹងវត្ថុដែលមានចលនាលឿន។ ហេតុនេះហើយ ទើបយើងពិបាកនឹងចាប់សត្វរុយបានណាស់។



## ស្រមោច

កូនសត្វឥតឆ្អឹងកងភាគច្រើនបែកគ្នាយ៉ាងឆាប់រហ័ស ដើម្បីទៅរស់នៅរៀងខ្លួន។ ប៉ុន្តែសត្វប្រភេទខ្លះរស់នៅជាក្រុមអចិន្ត្រៃយ៍ ជាហ្វូង ដូចជា កណ្ដៀរ ស្រមោច ឬឃ្មុំ។ សមាជិកក្នុងក្រុមនេះពឹងពាក់គ្នាទៅវិញទៅមក។ មានតែរាជិនីម្នាក់ឯងប៉ុណ្ណោះ ដែលពង។ សត្វឯទៀតក្នុងក្រុមមានមុខងារឯកទេសរៀងៗខ្លួន ដូចជារកស្បៀងអាហារ ធ្វើសំបុក ការពារក្រុមជាដើម។

# អាកត្រូប៉ូត-សត្វល្អិត

**អាកត្រូប៉ូត(arthropode) ទាំងអស់មានគ្រោងឆ្អឹងក្រៅ ដងខ្លួនចែកជាកង់ៗ និងជើងមានសន្លាក់។ ក្រុមនេះមានសត្វល្អិត ត្រូស្តាសេ(crustacé) អារ៉ាក់នីត(arachnide) និងសតបទីសត្វ។ ពួកសត្វល្អិតមានចំនួនច្រើនជាងគេ និងជាក្រុមសត្វឥតឆ្អឹងកងតែមួយគត់ដែលចេះហើរ។**




## សត្វកណ្តូប

កណ្តូបរស់នៅគ្រប់ទីកន្លែង លើកលែងតែនៅតំបន់ត្រជាក់ខ្លាំង។ វាមានប្រវែងពី១,៥សម ទៅ៧,៥សម។ វាមានស្លាបធំៗ តែវាច្រើនប្រើជើងក្រោយដែលធំហើយខ្លាំងទៅវិញ ដើម្បីលោតគេចពីគ្រោះថ្នាក់។ វាមានសម្បុរត្នោត ឬបៃតង តែកណ្តូបជាច្រើនមានសម្បុរដូចស្លឹកឈើ ឬសំបកឈើដើម្បីងាយលាក់ខ្លួន។ ដើម្បីទាក់ទាញមេ កណ្តូបឈ្មោលស្រែក ដោយត្រដុសស្លាបរឹងរបស់វា។ កណ្តូបមេពងនៅក្នុងសំបកឈើ ឬនៅក្នុងដី។ កណ្តូបស៊ីស្លឹកឈើ ឬស្មៅជាអាហារ ប៉ុន្តែជួនកាលនៅពេលយប់ វាក៏ចាប់សត្វល្អិតតូចៗ យកមកស៊ីផងដែរ។

**ខ្លួនរបស់សត្វល្អិតចែកចេញជាបីផ្នែក :**

- **ក្បាលមានភ្នែក និងពុក។**
- **នៅលើទ្រូងរបស់វា មានជើង៦ ហើយជាទូទៅមានស្លាប៤។**
- **ពោះមានសរីរាង្គរំលាយអាហារ និងប្រដាប់បន្តពូជ។**



## សត្វកញ្ចែ

កញ្ចែឈ្មោលមានគង្កៀបធំៗ ដែលវាប្រើសម្រាប់ប្រយុទ្ធ ប៉ុន្តែវាគ្មានពិសទេ។ វាស៊ីជ័ររុក្ខជាតិជាអាហារ។ សត្វកញ្ចែធំបំផុតមានប្រវែង១០សម។ សត្វកញ្ចែភាគច្រើនមានពណ៌ខ្មៅ ឬពណ៌ត្នោត ដែលគេឃើញមានច្រើននៅតំបន់ក្តៅ។ សត្វមេពងស៊ុតនៅក្នុងរន្ធដង្គត់ឈើ ឬឈើងាប់។ ក្រោយពេលញាស់កូនវាស៊ីសាច់ឈើជាអាហារ។





## មេអំបៅ

មេអំបៅធំបំផុតនៅលើពិភពលោក មានទទឹងប្រវែង២៨សម ហើយរស់នៅក្នុងព្រៃនៃប្រទេសប៉ាពូអាស៊ី-នូវែល-គីណេ។ មេអំបៅទាំងអស់កើតមកមានរូបរាងជាដង្កូវ ដែលស៊ីស្លឹកឈើជាអាហារ។ បន្ទាប់មក វាឈប់ស៊ីអាហារ ហើយធ្វើសំបុកដឹកឡើ និងរស់នៅក្នុងនោះ ដើម្បីប្រែរូបទៅជាសត្វពេញវ័យ។ មេអំបៅពេញវ័យស្រូបទឹកដមផ្កាជាអាហារ។ ស្លាបវាមានស្រកាតូចៗជាច្រើន។ ពណ៌មេអំបៅមួយចំនួនអាស្រ័យតាមរុក្ខជាតិ ដែលវាស៊ីមុននឹងក្លាយទៅជាមេអំបៅ។ វាក៏ប្រើស្លាបសម្រាប់ស្រូបយកថាមពលពីព្រះអាទិត្យផងដែរ ដើម្បីធ្វើឱ្យកំដៅក្នុងខ្លួនឡើងមុននឹងអាចហើរបាន។

### ការការពារខ្លួន

ដើម្បីគេចខ្លួនពីសត្រូវ ដង្កូវមេអំបៅប្រើមធ្យោបាយច្រើនយ៉ាង។ សត្វខ្លះបន្លំខ្លួនដោយយកពណ៌ ឬទំរង់ដូចរុក្ខជាតិដែលវាស៊ីជាអាហារ។ សត្វខ្លះទៀតស៊ីរុក្ខជាតិពុល ដើម្បីឱ្យខ្លួនវាមានជាតិពុល។ ដូច្នេះបក្សីដែលធ្លាប់មានពិសោធន៍ដឹងថា មិនត្រូវស៊ីដង្កូវទាំងនោះទេ។

# អាកត្រូប៉ូតផ្សេងៗទៀត



**ក្រុស្តាសេ អារាក្នីត និងសតបទីសត្វក៏ជាអាកត្រូប៉ូតដែរ។ ពួកវាមានគ្រោងឆ្អឹងក្រៅ ដងខ្លួនចែកជាកង់ៗ និងជើងមានសន្លាក់។**

## ក្តាម និងក្រុស្តាសេ

ក្តាមជាក្រុស្តាសេ។ មានក្តាមប្រភេទម្យ៉ាងរស់នៅលើឆ្នេរសមុទ្រនៃប្រទេសក្តៅ។ សត្វឈ្មោលមានតង្កៀបមួយធំ ដែលវាបិទបើកៗរឿយៗ ដើម្បីទាក់ទាញក្តាមញី និងសម្លុតគូប្រជែង។ តង្កៀបនេះមានទម្ងន់ប្រហែលពាក់កណ្តាលទម្ងន់ខ្លួនវាទាំងមូល។ ក្រុស្តាសេភាគច្រើន ដូចជាបង្កង និងបង្គារស់នៅក្នុងទឹកសាប ឬនៅក្នុងសមុទ្រ។ ពួកវាមានសំបកការពារខ្លួន និងរកផ្លូវដោយប្រើពុកទាំងពីរគូ។ ជើងមានតួនាទីច្បាស់លាស់ : ជើងខ្លះប្រើសម្រាប់ដើរនិងហែល ឯជើងខ្លះទៀតសម្រាប់ស្ទាបការពារខ្លួន កាត់អាហារ ឱបសត្វញី ឬសម្រាប់ដកដង្ហើម។

## អ្នកជួលមានសំណាង

សត្វខ្ញីព្រាណ(ក្រុស្តាសេ)ជាក្តាមសមុទ្រម្យ៉ាង ដែលតាំងលំនៅក្នុងសំបកខ្យងទទេ ហើយធ្វើដំណើរដោយនាំសំបកនោះទៅជាមួយ។ នៅពេលវាធំ វាក៏ចោលសំបកនោះ ហើយទៅនៅក្នុងសំបកថ្មីមួយទៀត ដែលធំជាង។



## ពីងពាង និងអារាក្នីត

ពីងពាងជាអារាក្នីតមួយប្រភេទ ដែលអាចមានសមត្ថភាពផលិតសរសៃសូត្រសម្រាប់ធ្វើសំបុក ឬសំណាញ់ ដោយសារក្រពេញនៅក្នុងពោះ។ វាត្បាញសរសៃសូត្រនោះធ្វើជាសំបុករាងមូលសម្រាប់ចាប់រំពា។ នៅពេលមានរំពាមកជាប់សំណាញ់ហើយ វាស្ទុះទៅរុំព័ទ្ធរំពានោះដោយសរសៃសូត្រ រួចស៊ីទៅ។ ខ្សែសូត្រនេះមានតួនាទីការពារពងទៀតផង។ ពួកអារាក្នីតក៏មានខ្យាដំរី ខ្ទួយ ចចាក់ម្សៅ... ផងដែរ។ ពួកវាមានដងខ្លួន ដែលចែកចេញជាពីរផ្នែក និងមានជើង៨ ក្នុងនោះមានជើង៤សម្រាប់ដើរ។ ពួកវាភាគច្រើនរស់នៅលើគោក ហើយស៊ីសត្វល្អិតតូចៗជាអាហារ។





## ក្អែប និងសតបទីសត្វ

ក្អែបជាសតបទីសត្វម្យ៉ាង ដែលមានជើងប្រមាណជា៤០ និងអាចមានប្រវែងពី៣ ទៅ៣០សម ទៅតាមប្រភេទរបស់វា។ វាច្រើនរស់នៅតំបន់ក្តៅ លាក់ខ្លួននៅក្នុងដី និងក្នុងសំណល់រុក្ខជាតិ។ វាជាសត្វរំពារកស៊ីពេលយប់ ហើយមានចង្កូមពិសជាអាវុធ។ ពេលវាខាំ ពិសវាអាចធ្វើឱ្យមនុស្សឈឺចាប់។ ក្អែបធំៗអាចវាយប្រហារកណ្តុរ និងកង្កែបបាន។ នៅក្នុងក្រុមសតបទីសត្វ ក៏មានម្រើមព្រះផងដែរ ដែលគេប្រទះឃើញសត្វខ្លះមានជើងច្រើនរហូតដល់៧៥០។



### ខ្យាដំរី

ខ្យាដំរី (អារាក្នីត) មានទ្រនិចពិសនៅចុងកន្ទុយ ដែលវាប្រើសម្រាប់សម្លាប់រំពា និងការពារខ្លួន។ ខ្យាដំរីធំបំផុតអាចមានប្រវែង២១សម។

# សត្វឥតឆ្អឹងកងឯទៀតៗ

ក្រៅពីពួកអាគ្រូប៉ូត នៅមានសត្វឥតឆ្អឹងកងសំខាន់ៗជាង៣០ក្រុមទៀត។ ក្រុមធំៗមាន សិប្បីសត្វ(mollusque) ដង្កូវខ្លួនកង់(ver annelé) គ្នីដែ(cnidaire) អេគីណូឌែម(échinoderme) និងស្ប៉ុងស៊ៀ(spongiaire)។



### សំបក

សំបកខ្យង និងសំបកសិប្បីសត្វដទៃទៀតជាជំរកលាក់ខ្លួន ក្នុងករណីមានគ្រោះថ្នាក់។ សំបកមានជាតិថ្មកំបោរ។ ខ្យងផលិតសំបក ដោយបញ្ចេញសារធាតុរាវ ដែលឡើងរឹងនៅពេលប៉ះនឹងខ្យល់ ឬទឹក។ នៅពេលខ្យងធំ សំបកវាក៏រីកធំដែរ។

### មឹកធំ និងសិប្បីសត្វ

មឹកធំជាសិប្បីសត្វមួយប្រភេទ ដែលរស់នៅឯកោក្នុងទឹកតាមឆ្នេរនៃសមុទ្រក្តៅ និងត្រជាក់បង្គួរ។ ដោយខ្លួនរបស់វាទន់ វាអាចចូលពួនក្នុងក្រហែងថ្មចង្អៀតៗបាន។ វាអាចផ្លាស់ទី និងក្រវីផ្ទាំងថ្មដើម្បីចាប់រំពាដោយប្រើដៃវែងៗ ប្រដាប់ដោយឈ្នាប់ជាច្រើន។ គួរឱ្យឆ្ងល់ដែរ មឹកធំមានសមត្ថភាពចេះធ្វើតាម ដោយគ្រាន់តែសង្កេតមើលគ្នាវាប៉ុណ្ណោះ។ គ្រំ ខ្យង និងខ្យងគ្មានសំបកក៏ស្ថិតនៅក្នុងក្រុមសិប្បីសត្វនេះដែរ។ សិប្បីសត្វខ្លះមានខ្លួនទន់ជ្រកនៅក្នុងសំបករឹង ឯខ្លះទៀតគ្មានសំបកទេ។



## ជន្លេន និងដង្កូវខ្លួនកង់

ជន្លេនជាដង្កូវខ្លួនកង់។ វាគ្មានជើងទេ ឯខ្លួនវាខ័ណ្ឌជាកង់ៗនៅជាប់គ្នា។ វារស់នៅក្នុងដីសើម និងស៊ីរូបធាតុរុក្ខជាតិជាអាហារ។ វាជីករូងដោយត្បុលដីសើម លេបដី និងកិនរំលាយអ្វីៗដែលវាអាចរំលាយបាន រួចបញ្ចេញសំណល់ចោលវិញ។ វាផ្លាស់ទីដោយបង្រួញនិងពន្លូតខ្លួន ដែលយើងមើលឃើញហាក់ដូចជាវាធ្វើចលនាបត់បែន។ ដង្កូវខ្លួនកង់មានច្រើនប្រភេទ ហើយខ្លះមានប្រវែងដល់ទៅ៣ម។ ពួកវារស់នៅក្នុងដី ឬនៅក្នុងកំទេចកំណនៅបាតទន្លេ ឬបាតសមុទ្រ។

### ឈ្លើង

ឈ្លើង(ដង្កូវខ្លួនកង់)ជាសត្វបរាសិត។ វាតោងជាប់នឹងស្បែកសត្វដែលវាខាំ ដោយសារឈ្នប់នៅចុងទាំងសងខាងនៃខ្លួនវា ហើយជញ្ជក់ឈាម។

## មេដុយ និងថ្នីនៃ

មេដុយ ឬពពុះទឹក ឬខ្លែងសមុទ្រជាថ្នីនៃ។ វាហែលទៅមុខដោយកន្ត្រាក់ខ្លួនប្រហោងរបស់វារាងដូចជួងដើម្បីបាញ់ទឹកចេញ និងរុញខ្លួនវាឱ្យរំកិលទៅមុខ។ ដៃវាមានពិសដែលអាចរោល ធ្វើឱ្យរំពាខ្វិន និងស្លាប់បាន។ មេដុយខ្លះអាចមានវិមាត្រដល់ទៅ២ម និងដៃមានប្រវែងច្រើនម៉ែត្រ។ អានេម៉ូនសមុទ្រ និងផ្កាថ្មក៏ស្ថិតក្នុងក្រុមថ្នីនៃនេះដែរ។ ថ្នីនៃទាំងអស់ជាសត្វរស់នៅក្នុងទឹក។ សត្វខ្លះហែលដោយសេរី ចំណែកឯសត្វខ្លះទៀតភ្ជាប់ខ្លួនទៅនឹងវត្ថុរឹង។



### ផ្កាថ្ម

ផ្កាថ្ម (ថ្នីនៃ) កើតពីសត្វតូចៗដែលមានគ្រោងឆ្អឹងសំបូរដោយជាតិថ្មកំបោរ ហើយដែលគេហៅថា ប៉ូលីប។ ពួកវារស់នៅដោយគរលើគ្នា ហើយបង្កើតជាផ្ទាំងថ្មប៉ប្រះទឹក។ ពួកវាស៊ីរុក្ខជាតិ និងប្លង់តុង ដែលអណ្តែតក្នុងទឹក។ នៅប្រទេសកម្ពុជា គេឃើញមានផ្កាថ្ម នៅក្នុងទឹកមិនសូវជ្រៅ ក្បែរៗឆ្នេរជុំវិញកោះមួយចំនួន។



# សត្វឥតឆ្អឹងកងឯទៀតៗ



## ផ្កាយសមុទ្រ និងអេគីណូឌែម

ផ្កាយសមុទ្រជាសត្វមួយក្នុងក្រុមអេគីណូឌែម។ ជាទូទៅ វាមានខ្លួនមូល និងដៃប្រាំស្មើៗគ្នាដុះចេញពីខ្លួន។ វាផ្លាស់ទីយឺតៗ ដោយប្រើជើងតូចៗរាងដូចបំពង់ដែលស្ថិតនៅលើផ្ទៃមុខខាងក្រោម។ ផ្កាយសមុទ្រខ្លះលេបរំពាតូចៗទាំងមូល ឯខ្លះទៀតអាចបញ្ចេញក្រពះតាមមាត់ឱ្យចេញមកខាងក្រៅដើម្បីរុំព័ទ្ធ និងរំលាយរំពាតែម្តង។ សត្វខ្លះអាចមានវិជ្ជមាត្រដល់១ម។ ក្រុមអេគីណូឌែម ក៏មានតាអន់។ ពួកវាទាំងអស់ជាសត្វរស់នៅក្នុងទឹក និងមានគ្រោងឆ្អឹងក្រៅដែលសំបូរទៅដោយជាតិថ្មកំបោរ។



## តាអន់ ឬអូសាំង

**បន្លាវែងការពារខ្លួនតាអន់ (អេគីណូឌែម) ប្រឆាំងនឹងសត្រូវរបស់វា។ មាត់ដែលស្ថិតនៅក្រោមខ្លួន មានធ្មេញ៥តម្រៀបគ្នាជារង្វង់។ តាអន់លាក់ខ្លួននៅក្នុងជ្រួរថ្មប្រេះទឹកនៅពេលថ្ងៃ ហើយចេញរកស៊ីនៅពេលយប់។ សត្វធំបំផុតអាចមានវិជ្ជមាត្រដល់ទៅ៣៥សម។**

## អេប៉ុង និងស្ប៉ុងសៀ

កាលពីដើម អេប៉ុងត្រូវគេចាត់ទុកថាជារុក្ខជាតិ ប៉ុន្តែតាមពិតវាជាសត្វដែលមានរូបរាងសាមញ្ញបំផុត។ វាមានកោសិកាសាច់ដុំចំនួនតិចបំផុត ហើយគ្មានកោសិកាប្រសាទទេ។ វាមានរាងជាស៊ីឡាំងបិទនៅចុងម្ខាង ហើយភ្ជាប់ខ្លួនទៅនឹងផ្ទាំងថ្ម។ ដើម្បីចិញ្ចឹមជីវិត វាបឺតទឹកចូល ហើយត្រងយកសារធាតុចិញ្ចឹម រួចបញ្ចេញទឹកចោលមកក្រៅវិញ។ អេប៉ុងខ្លះតូចល្អិត ខ្លះទៀតអាចមានកម្ពស់ជាង១ម។ ពួកវាច្រើនរស់នៅក្នុងឈូងសមុទ្រ។



# សាកល្បងរកចំលើយ

ពេលនេះប្អូនបានអានសៀវភៅ **ខ្ញុំចង់ដឹង** មួយក្បាលនេះចប់ហើយ តើប្អូនៗចងចាំបានអ្វីខ្លះ? ឥឡូវចូរប្អូនៗ សាកល្បងឆ្លើយសំណួរខាងក្រោមនេះ :

**1 តើឥន្ទិកសត្វធំណា មានស្បែករឹងជាងគេ?**
- ដំរី
- សត្វកវែង
- រមាស

**2 តើឥន្ទិកសត្វទឹកណា មានប្រវែងស្មើនឹងដំរី៦ក្បាល?**
- ផ្សោត
- បាឡែន
- សត្វផ្ទុក

**3 តើបក្សីណា មានស្លាបវែងជាងគេ?**
- ក្រសៀលកាំ
- ក្ងោក
- មៀម

**4 តើមានអ្វីនៅក្នុងប្តូករបស់អូដ្ឋ?**
- មានអីវ៉ាន់
- មានទឹក
- មានខ្លាញ់

**5 តើក្រពើមានធ្មេញប៉ុន្មាន?**
- ១០០
- ៦០
- ៣០

**6 ហេតុអ្វីបានជាអណ្តើកមាសមានស្នាមអុជៗ?**
- ដើម្បីឱ្យមានសម្រស់ស្អាត
- ដើម្បីសម្គាល់អាយុ
- ដើម្បីធ្វើឱ្យសត្វអ្នកប្រមាញ់ខ្លាច

**7 តើបក្សីណា ពងស៊ុត ធំជាងគេ?**
- សត្វម៉ង់ស្ទ
- ចាបចង្រុង
- សត្វអូទ្រុស

**8 ហេតុអ្វីបានជាពស់លៀនអណ្តាតឥតឈប់ឈរ?**
- ដើម្បីបន្លាចគេ
- ដើម្បីហិតក្លិន
- ដើម្បីខាំ ឬចឹកគេ

## ចំលើយ

1. គឺសត្វរមាស។ ស្បែកវាមានកម្រាស់២សម។
2. គឺត្រីបាឡែនខៀវ ដែលអាចមានប្រវែងដល់ទៅ៣០ម។
3. គឺសត្វក្ងោក។ ស្លាបវាអាចមានប្រវែងដល់ទៅ២ម។
4. នៅក្នុងប្តូករបស់អូដ្ឋ មានខ្លាញ់ដែលជាអាហារបំរុងរបស់វា។
5. ក្រពើមានធ្មេញ៦០ ដែលដុះសាជាថ្មី នៅពេលធ្មេញចាស់បាក់។
6. គឺដើម្បីធ្វើឱ្យសត្វអ្នកប្រមាញ់ខ្លាច ដោយគិតថា ខ្លួនវាមានជាតិពុល។
7. គឺសត្វអូទ្រុស ដែលពងជាស៊ុតមួយធំប្រហែល១.៥គក។
8. គឺដើម្បីហិតក្លិន។

## ពន្យល់ពាក្យ

**ការកូន** ភាពដែលសត្វញីមិនឲ្យចូលមកជិតកូនតូចៗ។

**ក្រាបពង** ក្រាបលើពងដើម្បីផ្តល់កំដៅឲ្យស៊ុតញាស់។

**ខ្សែអាហារ** សំណុំសត្វនិងរុក្ខជាតិ ដែលស៊ីគ្នាដើម្បីចិញ្ចឹមជីវិត។

**ត្បាញ** បណ្តាញដែលត្បាញ គឺលើរបស់ផុះទាប ដើម្បីចាប់សត្វខ្លះយកធ្វើជាចំណី។

**ល្បប់** សរីរាង្គរបស់សត្វខ្លះប្រើសម្រាប់ចាប់ភ្ជាប់ខ្លួនវាទៅនឹងអ្វីមួយ (ឈើ ទឹកដំ)។

**ដែនដី** តំបន់ការពារដោយសត្វមួយក្បាល ឬមួយក្រុមទល់នឹងសត្វឯទៀតប្រភេទដូចគ្នា។

**ទីឃជង្ឃបក្សី** ពួកបក្សីជើងវែងៗ ដូចជាកុក ក្រសា...។

**ប្លង់តុង** ភាវៈរស់ (សត្វ ឬរុក្ខជាតិ) តូចល្អិតៗ ដែលអណ្តែតក្នុងទឹកសាប ឬទឹកប្រៃ។

**ប្រភេទ** ក្រុមភាវៈរស់ដែលមានរូបរាងនិងលក្ខណៈស្រដៀងគ្នា ហើយអាចបង្កាត់គ្នានៅក្នុងធម្មជាតិ។

**ព្រីម៉ាត** ថនិកសត្វដែលមានមេដៃ ប្រឈមនឹងម្រាមឯទៀត។ ក្រុមនេះមានញ្ញាណពេញលេញនិងខួរក្បាលរីកចម្រើន ដូចជាស្វានិងមនុស្ស។

**ព្រៃរបោះ** ឬ **ព្រៃល្បោះ** ព្រៃដែលមានដើមឈើជ្រុះស្លឹកៗ ឃ្លាតៗ ដាច់ៗពីគ្នា។

**វិវត្ត** ឬ **ការវិវត្ត** ការផ្លាស់ប្តូរជាបន្តបន្ទាប់នឹងក្នុងកាលយូរអង្វែងនៃទម្រង់សត្វនិងរុក្ខជាតិ ដែលនាំឲ្យកើតទម្រង់ថ្មីៗ។

**សត្វរំពា** សត្វកាចសាហាវស៊ីរំពា ដែលជាសត្វឯទៀត។ **រំពា** សត្វមានជីវិតដែលសត្វសាហាវចាប់យកស៊ីជាអាហារ។

**សមត្ថ** សមត្ថភាពនឹងធ្វើអ្វីមួយ។

**សតបាទសត្វ** សត្វមានជើងច្រើន ដូចជាខ្យែប ក្អើមព្រះ...។

**សាយកូន** ដែលបង្កើតកូនច្រើន។

**សារពាង្គកាយ** ភាវៈមានជីវិតជាសត្វ ឬរុក្ខជាតិ។

**សំកាំង** ហើរដោយរក្សាស្លាបនៅលាតត្រដាង ហើយមិនបក់។

## ការថ្លែងអំណរគុណ

**យើងខ្ញុំសូមអរគុណជាពិសេស** ចំពោះក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា, នាយកដ្ឋានជលផល ក្រសួងកសិកម្ម, Institut de recherche pour le Développement (IRD), International Fund for Animal Welfare (IFAW), Wildlife Conservation Society (WCS), World Wildlife Fund (WWF), Conservation International (CI), Scuba Nation Diving Centre, Aquarium La Rochelle, La ferme aux crocodiles, Stéphanie Meng, Bios និងចំពោះអ្នកដែលបានចូលរួមសហការដើម្បីបោះពុម្ពផ្សាយសៀវភៅនេះ។ យើងខ្ញុំសូមអរគុណចំពោះ Clotilde Eav, Pascal Rafaud, ជ្រឹម ហុកស្រ៊ិន, និងអ្នកដែលបានចូលរួមសហការដើម្បីបោះពុម្ពសៀវភៅនេះ។

## សិទ្ធិលើរូបថត

**រូបគំនូរ** សាលី វណ្ណសុជាតា និង ខាត់ ដុលមាយរ៉ា

**រូបថត(ពីលើចុះក្រោម និងពីឆ្វេងទៅស្តាំ)** : **ក្របមុខ** : Meng - **ក្របទី២** : IFAW/Hrusa - **ទំព័រ1** : Bios/Klein & Hubert - **ទំព័រ2-3** : IFAW/Cook, Dorling Kindersley/Keates-Courtesy of the Natural History Museum-London, Bios/Klein & Hubert, Bios/Klein & Hubert, IRD/Gillon, IRD/Degallier, Phone/Labat, Dorling Kindersley/Minister, Bios/Gilson, Aquarium La Rochelle, Phone/Labat & Lanceau, Bios/Migeon, IRD/Laboute, IRD/Laboute - **ទំព័រ4-5** : IFAW/Samson, Bios/Klein & Hubert, អ៊ុក វណ្ណា - **ទំព័រ6-7** : Bios/Klein & Hubert - **ទំព័រ8-9** : IFAW/Willetts, Meng, Bios/Ruoso, IFAW/Hrusa - **ទំព័រ10-11** : Bios/Klein & Hubert, Bios/Klein & Hubert - **ទំព័រ12-13** : Colin, IFAW/SOTW, WDCS/Beasley, IFAW/Cook - **ទំព័រ14-15** : Bios/Klein & Hubert - **ទំព័រ16-17** : IRD/Gillon, Bios/Étienne, Bios/Mafart-Renodier - **ទំព័រ18-19** : Bios/Torterotot, Bios/Cavignaux - **ទំព័រ20-21** : IRD/Gillon - **ទំព័រ22-23** : IFAW/marinecreatures.com, La ferme aux crocodiles, Bios/Harvey, La ferme aux crocodiles - **ទំព័រ24-25** : Fotosearch, Bios/Sauvanet, Bios/Sauvanet - **ទំព័រ26-27** : IRD/Degallier - **ទំព័រ28-29** : Bios/Heuclin, Bios/Watts - **ទំព័រ30-31** : Phone/Labat, IRD/Séret - **ទំព័រ32-33** : Phone/Labat & Lanceau - **ទំព័រ34-35** : IFAW/James, Scuba Nation Diving Centre/Burns - **ទំព័រ36-37** : Aquarium La Rochelle, Aquarium La Rochelle, Scuba Nation Diving Centre/Burns, Aquarium La Rochelle/Prévost - **ទំព័រ38-39** : Bios/Matt - **ទំព័រ40-41** : Bios/Gilson, Bios/Gilson, Bios/Gilson - **ទំព័រ42-43** : Aquarium La Rochelle, Bios/Fève, IRD/Gillon - **ទំព័រ44-45** : Aquarium La Rochelle, Phone/Labat & Lanceau, Scuba Nation Diving Centre/Burns, Bios/Migeon - **ទំព័រ46-47** : IRD/Laboute, IRD/Laboute

IFAW
www.ifaw.org

SIPAR

© Éditions SIPAR 2011

ផ្ទះលេខ9 ផ្លូវ21
ប្រអប់សំបុត្រ31
ភ្នំពេញ - កម្ពុជា
ទូរស័ព្ទ : 855-23 216 001
edition@sipar-cam.org
www.sipar-books.com

រាល់ការចំលងទាំងស្រុង ឬ ផ្នែកណាមួយនៃសៀវភៅនេះ ទោះបីតាមរបៀបណាក៏ដោយ ដោយគ្មានការយល់ព្រមពីអង្គការSIPAR គឺខុសច្បាប់ និងត្រូវមានទោស។ រក្សាសិទ្ធិចំលង និងបកប្រែ ចំពោះគ្រប់ប្រទេសទាំងអស់។

បោះពុម្ពលើកទី៣
នៅប្រទេសកម្ពុជា
ដោយរោងពុម្ព
Digital Advertising

សូមអរគុណចំពោះ
Fondation Blancmesnil
de l'Institut de France
ដែលបានជួយឧបត្ថម្ភ
ដល់ការបោះពុម្ពលើកទី១

អំណោយ
អ្នកឧកញ៉ា ចន្ទ័_សារុន

# សៀវភៅនៃក្រុមសៀវភៅ ខ្ញុំចង់ដឹង
# ដែលបានចេញផ្សាយរួចហើយ :



















9789995054168

SIPAR